នស/រកម/០១១៦/ ០០៣

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល
លេខ ៣៣៩
ថ្ងៃទី ០៤/០២ ឆ្នាំ២០១៦ ម៉ោង ១៥:០០
បញ្ជូនទៅ ៤-៧

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# សុខភាពសត្វ
# និងផលិតកម្មសត្វ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.-

ច្បាប់នេះមានគោលបំណងដូចតទៅ ៖

- ធានាការគ្រប់គ្រង និងការអភិវឌ្ឍសុខភាពសត្វ និងផលិតកម្មសត្វ
- ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន
- បង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ
- ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ
- ធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ ។

## មាត្រា ២.-

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៣.-

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៤.-

ព្រះរាជាណាចក្រកម្ពុជាកំណត់ថ្ងៃទី ៤ ខែ តុលា រៀងរាល់ឆ្នាំ ជាសត្តទិវាជាតិរួមជាមួយនឹងសត្តទិវាអន្តរជាតិ ។

## មាត្រា ៥.-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២

# សមត្ថកិច្ចគ្រប់គ្រង

## មាត្រា ៦.-

ការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ជាអង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមត្ថកិច្ចគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ៣

## ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ

### មាត្រា៧.-

ស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំផែនការអភិវឌ្ឍស្តីពី ការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដែលបង្ហាញពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ។

ផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវសម្រេចដោយរាជរដ្ឋាភិបាល និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

### មាត្រា៨.-

ផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវដាក់ចេញនូវគោលដៅរយៈពេលវែង និងអាទិភាពនានា ដើម្បីគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងកសាងសមត្ថភាពជំនាញដែលអាចបំពេញភារកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

ផែនការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវលើកឡើងនូវកម្មវិធីអភិវឌ្ឍសំខាន់ៗដូចខាងក្រោម ៖

១- ការពង្រឹង និងពង្រីកសេវាកម្មបសុព្យាបាល សុខភាពសាធារណៈបសុព្យាបាល ព្រមទាំងតាមដានជំងឺ និងពង្រឹងកម្មវិធីបង្ការ ទប់ស្កាត់ និងលុបបំបាត់ជំងឺ ។

២- ការអភិវឌ្ឍផលិតកម្មសត្វ ផលិតកម្មកែច្នៃបឋមផលិតផលសត្វ ការគ្រប់គ្រងផលិតផលមានដើមកំណើតពីសត្វ និងការចិញ្ចឹមសត្វតាមគ្រប់រូបភាព ព្រមទាំងការលើកកម្ពស់ការបង្កាត់ពូជសត្វ ការអភិរក្ស និងការអភិវឌ្ឍធនធានសេនេទិកពូជសត្វ ។ ក្នុងករណីផលិតកម្មដែលលើសពីការកែច្នៃបឋម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ការអភិវឌ្ឍទីផ្សារសត្វ និងផលិតផលសត្វ និងការលើកកម្ពស់ប្រព័ន្ធព័ត៌មានផលិតកម្មសត្វ ។

៤- ការធានាសុវត្ថិភាពផលិតផលសត្វពីហានិភ័យដែលបណ្តាលមកពីសុខភាពសត្វ និងពង្រឹងគុណភាពផលិតផលសត្វ តាមរយៈការអនុវត្តល្អប្រសើរលើផលិតកម្មសត្វ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៥- ការលើកកម្ពស់ប្រសិទ្ធភាពផលិតកម្ម បសុឱសថ និងចំណីសត្វ វត្ថុធាតុដើម និងសមាសធាតុនៅក្នុងផលិតកម្មសត្វ ។

៦- ការលើកកម្ពស់ភាពជាដៃគូរវាងផ្នែកសាធារណៈ និងផ្នែកឯកជន ក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

៧- ការលើកកម្ពស់សេវាកម្មបសុពេទ្យ ប្រព័ន្ធព័ត៌មានសុខភាពសត្វ ការត្រួតពិនិត្យជំងឺសត្វ ការបង្ការ ការទប់ស្កាត់ និងការលុបបំបាត់ជំងឺសត្វ ។

៨- ការលើកកម្ពស់សុខុមាលភាពសត្វ និងសុខភាពសាធារណៈ ការត្រួតពិនិត្យ ការបង្ការ ការទប់ស្កាត់ និងការលុបបំបាត់ជំងឺស៊ូណូស ។

៩- ការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បច្ចេកទេស និងសមត្ថភាពគ្រប់គ្រងក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១០- ការអភិវឌ្ឍកម្មវិធីស្រាវជ្រាវបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ សុខភាពសត្វ និងផលិតកម្មសត្វរួមជាមួយការរក្សា និងការអភិវឌ្ឍចំណេះដឹងប្រពៃណីក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១១- ការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសវិទ្យាសាស្ត្រក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ សម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១២- កម្មវិធីអភិវឌ្ឍផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

## ជំពូកទី ៤
## ជំងឺសត្វ
## ផ្នែកទី ១
## ជំងឺវិញ្ញត្តិ និងការទប់ស្កាត់

### មាត្រា ៩.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិចេញសេចក្តីប្រកាសជំងឺសត្វណាមួយជាជំងឺវិញ្ញត្តិ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុពេទ្យ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុពេទ្យ ត្រូវរក្សាបញ្ជីឈ្មោះជំងឺវិញ្ញត្តិដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

### មាត្រា ១០.-

ប្រជាពលរដ្ឋគ្រប់រូបដែលបានដឹង បានឃើញ ឬសង្ស័យថាសត្វបានឆ្លងជំងឺ ឈឺ ឬស្លាប់ដោយជំងឺ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

វិញ្ញត្តិ ឬជំងឺផ្សេងទៀត មានករណីយកិច្ចផ្តល់ព័ត៌មានដល់ភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ។

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់សត្វ ដែលបានដឹង បានឃើញ ឬសង្ស័យថាសត្វបានឆ្លងជំងឺ ឈឺ ឬស្លាប់ដោយសារជំងឺវិញ្ញត្តិ ឬជំងឺផ្សេងទៀត មានកាតព្វកិច្ចផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីមានសមត្ថកិច្ច ឬអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលក្នុងមូលដ្ឋានសាមី ។

## មាត្រា ១១.-

សត្វដែលបានឆ្លងជំងឺវិញ្ញត្តិ ត្រូវបានហាមការលក់ដូរ ការលែងចោល ការធ្វើចរាចរណ៍ ការបោះបង់ចោល ការពិឃាតដើម្បីយកផលិតផលធ្វើជាអាហារ លក់ដូរ កែច្នៃ ឬចែកចាយដល់សាធារណជន ។

ករណីសត្វ ឬផលិតផលសត្វដែលសង្ស័យថាបានឆ្លងជំងឺវិញ្ញត្តិ អង្គភាពជំនាញទទួលបន្ទុក ផលិតកម្ម និងបសុព្យាបាល អាចអនុញ្ញាតឲ្យធ្វើចរាចរណ៍បានក្នុងគោលបំណងទប់ស្កាត់ និងលុបបំបាត់ការរីក-រាលដាលនៃជំងឺសត្វ តាមគោលការណ៍ណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដោយអនុលោមតាមវិធានការបសុព្យាបាល ។

## មាត្រា ១២.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវសម្រេចលើវិធានការអនាម័យ ដើម្បីបង្ការ ការឆ្លងរាលដាលជំងឺវិញ្ញត្តិដូចខាងក្រោម ៖

- ហាមឃាត់ ឬដាក់កំហិតលើការធ្វើចរាចរណ៍សត្វ ផលិតផលសត្វ ឧបករណ៍ សម្ភារបរិក្ខារ ឬមធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ ដែលអាចជាប្រភពចម្លងរោគមកក្នុង ឬទៅក្រៅទីកន្លែងចិញ្ចឹម ឬទីកន្លែងប្រមូលផ្តុំសត្វដទៃទៀត

- ចាត់វិធានការអនាម័យនៅទីកន្លែងចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ឧបករណ៍ សម្ភារ ឬមធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងទីកន្លែងផ្សេងទៀតដែលសត្វ និងផលិតផលសត្វ ឬទំនិញអាចបង្កហានិភ័យនៃការឆ្លងរាលដាលជំងឺវិញ្ញត្តិ ។

## មាត្រា ១៣.-

ផ្អែកលើសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺវិញ្ញត្តិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសដូចខាងក្រោម ៖

១- ការកំណត់កន្លែងឆ្លងជំងឺសត្វ ។

២- ការកំណត់តំបន់ឆ្លងជំងឺសត្វ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

៣- ការកំណត់តំបន់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាជាតំបន់ត្រួតពិនិត្យ ឬតំបន់ទប់ស្កាត់ជំងឺ ។

៤- ការកំណត់តំបន់ណាមួយ ឬទីតាំងជីវសុវត្ថិភាពណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាតំបន់គ្មានជំងឺ ។

## មាត្រា ១៤.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវចាត់វិធានការអនាម័យនៅតាមកន្លែងឆ្លងជំងឺ និងតំបន់ទប់ស្កាត់ជំងឺ ដើម្បីបង្ការ ការឆ្លងរាលដាលជំងឺវិញ្ញត្តិ ដូចខាងក្រោម ៖

- ដាក់កំហិតលើចរាចរណ៍សត្វផលិតផលសត្វ ឧបករណ៍ សម្ភារប្រើប្រាស់ និងមធ្យោបាយដឹកជញ្ជូនពាក់ព័ន្ធដែលអាចធ្វើឲ្យជំងឺឆ្លងរាលដាល
- ហាមឃាត់នូវរបៀបផ្តល់ចំណី និងទឹកដល់សត្វ ដែលអាចធ្វើឲ្យជំងឺឆ្លងរាលដាល
- ដាក់ឲ្យនៅដោយឡែក សង្កេត បំបែក ឬធ្វើចត្តាឡីស័កសត្វឆ្លងជំងឺ ឬសត្វសង្ស័យឆ្លងជំងឺវិញ្ញត្តិ
- អង្កេតអេពីដេមីសាស្ត្រ
- អនុវត្តយន្តការសម្រាប់អត្តសញ្ញាណកម្មសត្វនៅក្នុងតំបន់ឆ្លងជំងឺ ឬតំបន់ត្រួតពិនិត្យជំងឺ
- អនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មសត្វ
- យកទៅធ្វើតេស្តវត្ថុវិភាគពីសត្វ ផលិតផលសត្វ ឧបករណ៍ ឬសម្ភារប្រើប្រាស់ពាក់ព័ន្ធដទៃទៀតដែលអាចចម្លងជំងឺ
- បង្ការជំងឺសត្វ និងការព្យាបាលសត្វ
- សម្អាត និងសម្លាប់មេរោគនៅតាមទីកន្លែងចិញ្ចឹមសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ឧបករណ៍ សម្ភារ និងមធ្យោបាយដឹកជញ្ជូន
- កម្ទេចចោលសត្វដែលឆ្លងជំងឺវិញ្ញត្តិ ឬសត្វដែលសង្ស័យមានជំងឺវិញ្ញត្តិ ដោយប្រើវិធីមិនឃោរឃៅ
- ឃាត់ទុក បំផ្លាញចោល ឬធ្វើប្រព្រឹត្តិកម្មតាមវិធានការបសុព្យាបាលចំពោះសាកសពសត្វ ផលិតផលសត្វ ឧបករណ៍ ឬសម្ភារដទៃទៀតដែលចាត់ទុកថាបានឆ្លង ឬប៉ះពាល់មេរោគ
- ចាត់វិធានការអនាម័យដទៃផ្សេងទៀតតាមការចាំបាច់ ។

វិធានការអនាម័យត្រូវធ្វើការវិភាគហានិភ័យដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបោះពុម្ពផ្សាយជាសាធារណៈ ។ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវជូនដំណឹងដល់អ្នកពាក់ព័ន្ធដើម្បីជានាតម្លាភាព ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## មាត្រា ១៥.–

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើផែនការសកម្មភាព និងផែនការត្រៀមបម្រុងសម្រាប់ទប់ស្កាត់ និងលុបបំបាត់ជំងឺវិញ្ញត្តិ ដើម្បីបង្ការការរីករាលដាលជំងឺវិញ្ញត្តិតាមសំណើអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

## មាត្រា ១៦.–

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវស្នើសុំការសហការពីស្ថាប័នសាធារណៈ ឬផ្នែកឯកជន ដើម្បីបង្ការ និងទប់ស្កាត់ជំងឺវិញ្ញត្តិក្នុងករណីចាំបាច់ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវស្នើសុំសហការពីក្រសួងសុខាភិបាល ដើម្បីរៀបចំកម្មវិធីនីតិវិធី និងសេចក្តីណែនាំសម្រាប់បង្ការ និងទប់ស្កាត់ជំងឺស៊ូណូស ។

# ផ្នែកទី ២
# ភាពអាសន្ននៃជំងឺសត្វ

## មាត្រា ១៧.–

ដោយមានការឯកភាពពីនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្តីពីការដាក់ភាពអាសន្ននៃជំងឺសត្វ និងចេញប្រកាសស្តីពីការរំសាយភាពអាសន្ននៃជំងឺសត្វតាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

## មាត្រា ១៨.–

ភាពអាសន្ននៃជំងឺសត្វ ត្រូវមានមូលនិធិសម្រាប់ដំណើរការ ។

មូលនិធិសម្រាប់ភាពអាសន្ននៃជំងឺសត្វមានប្រភពមកពី៖

- ថវិកាជាតិជាកញ្ចប់ដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ហិរញ្ញប្បទានដែលបានមកពីដៃគូអភិវឌ្ឍ
- ប្រភពផ្សេងទៀត ។

ការបង្កើតមូលនិធិសម្រាប់ភាពអាសន្ននៃជំងឺសត្វ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៥
# ផលិតកម្មសត្វ
## ផ្នែកទី ១
## ពូជសត្វ

**មាត្រា ១៩.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវលើកកម្ពស់ការគ្រប់គ្រងធនធានសេនេទិកសត្វ ប្រកបដោយនិរន្តរភាព តាមរយៈវិធានអភិរក្សពូជសត្វក្នុងស្រុក និងពូជថ្មីនៃសត្វ និងរក្សាចំណេះដឹងជាប្រពៃណីអំពីការបង្កាត់ពូជសត្វ និងអភិវឌ្ឍពូជថ្មីនៃសត្វដែលផ្តល់នូវផលិតភាពខ្ពស់ ។

**មាត្រា ២០.-**

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវសិក្សាស្រាវជ្រាវ បង្កើត និងធ្វើបច្ចុប្បន្នកម្មបញ្ជីពូជសត្វក្នុងស្រុកនៅព្រះរាជាណាចក្រកម្ពុជា ។

បញ្ជីពូជសត្វក្នុងស្រុកនៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មនាំចូល នាំចេញពូជសត្វ ឬផលិតពូជសត្វ ឬបង្កើតពូជថ្មីនៃសត្វ ត្រូវដាក់ពាក្យសុំការចុះបញ្ជី និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ពូជសត្វ ឬពូជថ្មីនៃសត្វនោះនៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

នីតិវិធីសម្រាប់ការផ្តល់វិញ្ញាបនបត្របញ្ជាក់ពូជសត្វក្នុងស្រុក ឬពូជថ្មីនៃសត្វត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូល និងការនាំចេញពូជសត្វក្នុងទម្រង់ជាសត្វរស់ ឬរូបធាតុសេនេទិកសត្វដទៃទៀត ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មផ្គត់ផ្គង់ចែកចាយសត្វ បង្កាត់ពូជ ឬរូបធាតុសេនេទិកសត្វ ត្រូវមានលិខិតអនុញ្ញាតចេញដោយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

នីតិវិធីសម្រាប់ការនាំចូល ការនាំចេញ និងការផ្គត់ផ្គង់ចែកចាយសត្វ បង្កាត់ពូជ ឬរូបធាតុសេនេទិកសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ២
## ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ

### មាត្រា ២៣.-

ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ព្រមទាំងការបង្កើតទីកន្លែងផលិត ឬសន្និធិផលិតផលសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវគ្រប់គ្រងតាមរយៈ ៖

- ការផ្តល់លិខិតអនុញ្ញាត
- ការចុះបញ្ជីពូជសត្វក្នុងស្រុក និងពូជថ្មីនៃសត្វ
- ការបង្កើតអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ ។

### មាត្រា ២៤.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អ្នកកាន់លិខិតអនុញ្ញាត ត្រូវចុះបញ្ជីកសិដ្ឋានរបស់ខ្លួន នៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ខ្នាតដូចខាងក្រោម ៖

- ខ្នាតតូច
- ខ្នាតមធ្យម
- ខ្នាតធំ ។

ចំណាត់ថ្នាក់ខ្នាត និងបទដ្ឋានបច្ចេកទេសសម្រាប់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ព្រមទាំងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ២៥.-

ការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វជាលក្ខណៈគ្រួសារ ឬលក្ខណៈប្រពៃណីដើម្បីបម្រើជីវភាពប្រចាំថ្ងៃមិនតម្រូវឲ្យមានលិខិតអនុញ្ញាតឡើយ ។

### មាត្រា ២៦.-

កសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មខ្នាតមធ្យម ខ្នាតធំ ដែលអនុញ្ញាតឲ្យបង្កើតតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវមានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវម្នាក់ដែលមានសញ្ញាបត្រ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

វិទ្យាសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ និងម្នាក់ទៀតមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ ។

បុគ្គលិកបច្ចេកទេសទទួលខុសត្រូវ ដែលជាបសុពេទ្យ ត្រូវចុះបញ្ជីទទួលស្គាល់ដោយគណៈបសុពេទ្យ ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ២៧.-**

ត្រូវបានហាមឃាត់ការចិញ្ចឹមសត្វដោយប្រើបសុឱសថ ឬចំណីសត្វដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស ។

**មាត្រា ២៨.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិព្រមាន ផ្អាក ព្យួរ ឬដកហូតលិខិតអនុញ្ញាតចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ក្នុងករណី ៖

- អ្នកកាន់លិខិតអនុញ្ញាតប្រព្រឹត្តផ្ទុយនឹងបទដ្ឋានបច្ចេកទេស ឬបទប្បញ្ញត្តិនៃច្បាប់នេះ
- មានភស្តុតាងបញ្ជាក់អំពីគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ដែលបង្កឡើងដោយសារការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វនោះ ។

## ផ្នែកទី ៣
## អត្តសញ្ញាណកម្មសត្វ

**មាត្រា ២៩.-**

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវលើកកម្ពស់ការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មសត្វ ក្នុងគោលបំណងបញ្ជាក់ម្ចាស់កម្មសិទ្ធិសត្វ គ្រប់គ្រងការចិញ្ចឹមសត្វ ការបង្កាត់ពូជសត្វ និងចរាចរណ៍សត្វ ដើម្បីទប់ស្កាត់ជំងឺឆ្លងសត្វ និងការពារសុខភាពមនុស្ស និងសត្វ ។

**មាត្រា ៣០.-**

សត្វគ្រប់ប្រភេទដែលចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ត្រូវមានអត្តសញ្ញាណសម្គាល់ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវរៀបចំកសាងសមត្ថភាព និងយន្តការនានាដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មសត្វ និងប្រព័ន្ធតាមដានប្រភពសត្វ ។

នីតិវិធីនៃការធ្វើអត្តសញ្ញាណកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ៦
## បសុឱសថ

**មាត្រា ៣១.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដាក់បញ្ញត្តិលើការធ្វើពាណិជ្ជកម្ម ការផលិត ការលាយផ្សំ ការចេញវេជ្ជបញ្ជា និងការប្រើប្រាស់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល និងសម្ភារបរិក្ខារបសុព្យាបាល ។

បសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ត្រូវចុះបញ្ជីសម្រាប់ការប្រើប្រាស់ជាក់លាក់ណាមួយដោយផ្អែកលើហានិភ័យចំពោះសុខភាពមនុស្ស និងសត្វ ។

បញ្ជីបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ដែលអនុញ្ញាតឲ្យប្រើប្រាស់ និងហាមឃាត់ការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូល ការនាំចេញ ការផលិត ឬធ្វើការលាយផ្សំបសុឱសថក្នុងគោលបំណងធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការចុះបញ្ជីប្រភេទបសុឱសថនោះជាមុនដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីបសុឱសថត្រូវបំពេញតាមការតម្រូវបមាណីយដោយត្រូវផ្តល់ព័ត៌មានពេញលេញ ត្រឹមត្រូវសម្រាប់ការពិនិត្យ និងការវាយតម្លៃ ។ ឯកសារស្តីពីយថាប្រភេទបច្ចេកទេសនៃប្រភេទបសុឱសថដែលចេញពីប្រទេសប្រភពដើមផលិត ឬលាយផ្សំ ត្រូវភ្ជាប់ជាចាំបាច់ ជាមួយសំណើសុំការចុះបញ្ជី ។

**មាត្រា ៣៣.-**

បសុឱសថគ្រប់ប្រភេទដែលស្នើសុំការចុះបញ្ជី ត្រូវឆ្លងកាត់ការធ្វើវិភាគដើម្បីផ្ទៀងផ្ទាត់សារធាតុសកម្ម ឬសមាសធាតុនៅមន្ទីរពិសោធន៍អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ។

បសុឱសថប្រភេទថ្មី ឬបសុឱសថដែលមានទិន្នន័យមិនគ្រប់គ្រាន់ សម្រាប់ការវាយតម្លៃលើសំណើសុំការចុះបញ្ជី តម្រូវឲ្យធ្វើការសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាពនៅស្ថានីយពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវកំណត់ពិធីសារសាកល្បងប្រសិទ្ធភាព និងគោលការណ៍ណែនាំសម្រាប់វិភាគបសុឱសថ ។

**មាត្រា ៣៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបដិសេធសំណើសុំការចុះបញ្ជីបសុឱសថផ្អែកតាមលក្ខណវិនិច្ឆ័យណាមួយដូចខាងក្រោម ៖

១- ព័ត៌មាន ទិន្នន័យ ដែលអះអាងក្នុងសំណុំបែបបទស្នើសុំការចុះបញ្ជីមានភាពមិនពិត ឬមិនទាន់មានទិន្នន័យស្រាវជ្រាវច្បាស់លាស់នៅព្រះរាជាណាចក្រកម្ពុជា ។

២- សារធាតុសកម្ម ឬសមាសធាតុមានកម្រិតមិនអនុលោមតាមបមាណីយអនុគ្រោះ សម្រាប់ការចុះបញ្ជី ។

៣- សារធាតុសកម្ម ឬសមាសធាតុ ត្រូវបានហាមឃាត់ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង សុខភាពសត្វ ឬដែលអាចបង្កហានិភ័យចំពោះសុខភាពមនុស្ស សត្វ និងបរិស្ថាន ។

ការតម្រូវបមាណីយបសុឱសថ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ផ្គត់ផ្គង់ចែកចាយ និងលក់ដុំ លក់រាយនូវបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាលគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់សកម្មភាព ដែលតម្រូវដោយនីតិវិធីនៃច្បាប់នេះ ។

នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសសម្រាប់សកម្មភាពនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៦.-**

សំបកវេចខ្ចប់នៃផលិតផលបសុឱសថដែលធ្វើពាណិជ្ជកម្ម ត្រូវផលិតពីវត្ថុធាតុដែលធានាមិនប្រែប្រួលលក្ខណៈរូប គីមី និងជីវៈនៃផលិតផលបសុឱសថ ។

ស្លាកសញ្ញាព័ត៌មាននៃផលិតផលបសុឱសថ ត្រូវតែមានជាភាសាខ្មែរ អាចអានបាន ងាយយល់ និងមិនងាយរលុប និងត្រូវបោះពុម្ពផ្ទាល់លើសំបកវេចខ្ចប់ ឬត្រូវប្រើបរិយាយបណ្ណព័ត៌មានបន្ថែមតាមការចាំបាច់ ។

ព័ត៌មានអប្បបរមា និងគំរូស្លាកសញ្ញាព័ត៌មានសម្រាប់បសុឱសថ ត្រូវបានកំណត់ក្នុងនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ៣៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល នាំចេញ នាំឆ្លងកាត់ និងចរាចរបសុឱសថនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ហាញលិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ ដើម្បីឲ្យមន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ ដោយត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម ៖

១- សម្រាប់ការនាំចូល ការនាំចេញ ត្រូវឆ្លងកាត់ការត្រួតពិនិត្យនៅតាមស្នាក់ការ ឬទីកន្លែងត្រួតពិនិត្យរបស់មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចប្រចាំការនៅកន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន ដែលកំណត់ដោយរាជរដ្ឋាភិបាល ត្រូវមានលិខិតអនុញ្ញាតនាំចូល នាំចេញ និងត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស សម្រាប់ការនាំចូល ការនាំចេញ ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

២- សម្រាប់ការនាំឆ្លងកាត់ ត្រូវអនុវត្តលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។

៣- សម្រាប់ចរាចរណ៍ដើម្បីផ្គត់ផ្គង់ចែកចាយក្នុងប្រទេស ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃការដឹកជញ្ជូនបសុឱសថ ត្រូវភ្ជាប់ជាមួយលិខិតអនុញ្ញាតសម្រាប់ផ្គត់ផ្គង់ចែកចាយស្របតាមនីតិវិធីនៃច្បាប់នេះ និងឯកសារពាក់ព័ន្ធដែលកំណត់នូវប្រភេទ បរិមាណ និងទីតាំង ឬគ្រឹះស្ថាន ដែលទទួលយកការផ្គត់ផ្គង់ចែកចាយ ។

បទដ្ឋានបច្ចេកទេសនៃការដឹកជញ្ជូនបសុឱសថ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៣៨.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយអង្គភាព និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីផ្អាក ឬបញ្ឈប់ការធ្វើពាណិជ្ជកម្មគ្រប់រូបភាព ការផលិត ការលាយផ្សំ និងលុបចោលវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទបសុឱសថ សារធាតុសកម្ម ឬវត្ថុធាតុជីវៈបសុព្យាបាលណាមួយក្នុងករណី ៖

១- មានទិន្នន័យស្រាវជ្រាវវិទ្យាសាស្ត្រចុងក្រោយរកឃើញថា ប្រភេទបសុឱសថ សារធាតុសកម្ម ឬវត្ថុធាតុជីវៈបសុព្យាបាលអាចបង្កគ្រោះថ្នាក់ចំពោះជីវិត ឬសុខភាពមនុស្សនិងសត្វ ផលិតកម្មសត្វ និងបរិស្ថាន ។

២- សមាសធាតុសម្រាប់ផ្សំបសុឱសថ សារធាតុសកម្ម ឬវត្ថុធាតុជីវៈបសុព្យាបាលណាមួយត្រូវបានហាមឃាត់ដោយអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលតម្រូវឱ្យផ្អាក ឬបញ្ឈប់ការធ្វើពាណិជ្ជកម្មគ្រប់រូបភាព ការផលិត ឬធ្វើការលាយផ្សំដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវទទួលខុសត្រូវប្រមូលមកវិញនូវប្រភេទបសុឱសថ សារធាតុសកម្ម ឬវត្ថុធាតុជីវៈបសុព្យាបាលទាំងនោះ ដើម្បីធ្វើប្រព្រឹត្តិកម្ម ឬបំផ្លាញចោលតាមវិធានការបសុព្យាបាល ស្របតាមនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ៣៩.-**

នីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ដែលធ្វើពាណិជ្ជកម្ម និងធ្វើការលាយផ្សំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

# ជំពូកទី ៧
## ចំណីសត្វ

**មាត្រា ៤០.-**

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមនៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម ការផលិត ការលាយផ្សំ និងការប្រើប្រាស់ ដើម្បីធានាសុខភាពសត្វ ធានានិរន្តរភាពផលិតកម្មសត្វ និងធានាសុវត្ថិភាព និងគុណភាពផលិតផលសត្វ ។ ក្នុងករណីការគ្រប់គ្រងការផលិតចំណីសត្វលើសពីកម្រិតកែច្នៃបឋម និងការលាយផ្សំលើសពីលក្ខណៈរូប-សាស្ត្រ អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា ៤១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូល ការនាំចេញចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ឬធ្វើការលាយផ្សំចំណីសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការចុះបញ្ជីប្រភេទចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមនោះជាមុន ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមមានកាតព្វកិច្ចបំពេញការតម្រូវបមាណីយដោយត្រូវផ្ដល់ព័ត៌មានពេញលេញ និងត្រឹមត្រូវសម្រាប់ការពិនិត្យ និងវាយតម្លៃ ។ ឯកសារប្រភពដើមស្ដីពីយថាប្រភេទបច្ចេកទេសនៃប្រភេទចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមត្រូវភ្ជាប់ជាចាំបាច់ជាមួយសំណើសុំការចុះបញ្ជី ។

បញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់លាយផ្សំចំណីសត្វនៅក្នុងព្រះរាជាណា-ចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះរាជទាំង

**មាត្រា ៤២.-**

ចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមគ្រប់ប្រភេទដែលស្នើសុំការចុះបញ្ជី ត្រូវឆ្លងកាត់ការធ្វើវិភាគ ដើម្បីរកភ្នាក់ងារចម្លងជំងឺ ផ្ទៀងផ្ទាត់សមាសធាតុ សារធាតុហាមឃាត់ ឬសារធាតុពុល ឬធ្វើការសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាព ។

ការធ្វើវិភាគត្រូវអនុវត្តនៅមន្ទីរពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ។

ការសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាព ត្រូវអនុវត្តនៅស្ថានីយពិសោធន៍សុខភាពសត្វ និងផលិតកម្មសត្វ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវកំណត់ពិធីសារសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាព និងគោលការណ៍ណែនាំសម្រាប់វិភាគចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ។

**មាត្រា ៤៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបដិសេធសំណើសុំការចុះបញ្ជីប្រភេទចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដោយផ្អែកតាមលក្ខណវិនិច្ឆ័យណាមួយដូចខាងក្រោម ៖

១- ព័ត៌មាន និងទិន្នន័យ ដែលអះអាងក្នុងសំណុំបែបបទសុំចុះបញ្ជីមានភាពមិនពិត ។

២- ការវិភាគ និងការសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាពមិនអនុលោមតាមគោលការណ៍ណែនាំសម្រាប់វិភាគ និងពិធីសារសាកល្បងប្រសិទ្ធភាព និងសុវត្ថិភាព ដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ ។

៣- ចំណីសត្វមិនបំពេញតាមបមាណីយ ឬដែលគ្មានសុវត្ថិភាពចំពោះមនុស្ស សត្វ និងបរិស្ថាន ។

៤- គ្មានអនាម័យ មិនស្របតាមបទដ្ឋានបច្ចេកទេស ឬមានភ្នាក់ងារចម្លងជំងឺដែលបង្កគ្រោះថ្នាក់ចំពោះជីវិត ឬសុខភាពមនុស្ស និងសត្វ ។

៥- សមាសធាតុសម្រាប់ផ្សំ ដែលត្រូវហាមឃាត់ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀង ឬមានសក្តានុពលភាពហានិភ័យចំពោះជីវិត ឬសុខភាពមនុស្ស សត្វ ផលិតកម្មសត្វ និងបរិស្ថាន ។

**មាត្រា ៤៤.-**

ការតម្រូវបមាណីយចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពនាំចូល នាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិ ផ្គត់ផ្គង់ចែកចាយ និងលក់ដុំលក់រាយនូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • ROYAL • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

បទដ្ឋានបច្ចេកទេស សម្រាប់សកម្មភាពនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៤៦.-

សំបកវេចខ្ចប់នៃផលិតផលចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ត្រូវផលិតពីវត្ថុធាតុដែលជាប់មាំល្អ ធន់នឹងធាតុអាកាស មិនបណ្តាលឲ្យប្រែប្រួលលក្ខណៈរូប និងគីមីនៃផលិតផល និងផ្តល់ភាពងាយស្រួលដល់ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ ។

ស្លាកសញ្ញាព័ត៌មាននៃផលិតផលចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែម ត្រូវតែមានជាភាសាខ្មែរ អាចអានបាន ងាយយល់ និងមិនងាយលុប ដោយត្រូវបោះពុម្ពផ្ទាល់លើសំបកវេចខ្ចប់ ឬត្រូវប្រើបរិយាយបណ្ណព័ត៌មានបន្ថែមតាមការចាំបាច់ ។

ព័ត៌មានអប្បបរមា និងគំរូស្លាកសញ្ញាព័ត៌មានសម្រាប់ចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមត្រូវបានកំណត់ក្នុងនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជី ។

## មាត្រា ៤៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ និងការចរាចរចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ហាញលិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ ដើម្បីឲ្យមន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចត្រួតពិនិត្យ ដោយត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម ៖

១- សម្រាប់ការនាំចូល ការនាំចេញ ត្រូវឆ្លងកាត់ការត្រួតពិនិត្យនៅតាមស្នាក់ការ ឬកន្លែងត្រួតពិនិត្យរបស់មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចប្រចាំការនៅកន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល ត្រូវមានលិខិតអនុញ្ញាតនាំចូល នាំចេញ និងត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស សម្រាប់ការនាំចូល ការនាំចេញ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

២- សម្រាប់ការនាំឆ្លងកាត់ត្រូវអនុវត្តលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។

៣- សម្រាប់ការចរាចរដើម្បីផ្គត់ផ្គង់ចែកចាយនៅក្នុងប្រទេស ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃការដឹកជញ្ជូនចំណីសត្វ ត្រូវភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតសម្រាប់ការផ្គត់ផ្គង់ចែកចាយស្របតាមនីតិវិធីនៃច្បាប់នេះ និងឯកសារពាក់ព័ន្ធដែលកំណត់នូវប្រភេទ បរិមាណ និងទីតាំង ឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ ។

បទដ្ឋានបច្ចេកទេសនៃការដឹកជញ្ជូនចំណីសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៨.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្អាកឬបញ្ឈប់ការចុះបញ្ជីការធ្វើពាណិជ្ជកម្ម គ្រប់រូបភាពនូវចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែម ការលាយផ្សំ និងលុបចោលវិញ្ញាបនបត្របញ្ជាក់បញ្ជិកាប្រភេទចំណីសត្វណាមួយក្នុងករណី ៖

១- មានទិន្នន័យស្រាវជ្រាវវិទ្យាសាស្ត្រចុងក្រោយរកឃើញថា ប្រភេទចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមនោះអាចបង្កគ្រោះថ្នាក់ចំពោះជីវិត ឬសុខភាពមនុស្ស និងសត្វ ផលិតកម្មសត្វ និងបរិស្ថាន ។

២- សមាសធាតុណាមួយសម្រាប់ផ្សំចំណីសត្វ ត្រូវបានហាមឃាត់ដោយអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលតម្រូវឲ្យផ្អាក ឬបញ្ឈប់ការធ្វើពាណិជ្ជកម្ម ឬការលាយផ្សំដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវទទួលខុសត្រូវប្រមូលមកវិញនូវប្រភេទចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែមទាំងនោះ ដើម្បីធ្វើប្រព្រឹត្តិកម្ម ឬបំផ្លាញចោលតាមវិធានការបសុព្យាបាលស្របតាមនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ៤៩.-**

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម ឬសារធាតុបន្ថែម ដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៨

## សត្តឃាតដ្ឋាន និងអនាម័យ

**មាត្រា ៥០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតសត្តឃាតដ្ឋាន ឬទីកន្លែងកែច្នៃបឋមផលិតផលសត្វត្រូវតែមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវចុះបញ្ជីសត្តឃាតដ្ឋាន និង/ឬទីកន្លែងកែច្នៃបឋមផលិតផលសត្វនោះ ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើការពិឃាតសត្វគ្រប់ប្រភេទក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ត្រូវអនុវត្តនៅក្នុងសត្តឃាតដ្ឋាន និងត្រូវមានលិខិតអនុញ្ញាតការធ្វើអាជីវកម្មពិឃាតសត្វចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៥១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់សត្តឃាតដ្ឋាន ធ្វើអាជីវកម្មពិឃាតសត្វ ឬកាន់កាប់ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដូចខាងក្រោម ៖

- ត្រូវសាងសង់សត្តឃាតដ្ឋានតាមបទដ្ឋានបច្ចេកទេស
- ត្រូវមានលិខិតអនុញ្ញាត និងត្រូវអនុវត្តតាមនីតិវិធីបង្កើតសត្តឃាតដ្ឋាន ពិឃាតសត្វ ឬបង្កើតទីកន្លែងកែច្នៃបឋមផលិតផលសត្វ ព្រមទាំងត្រូវអនុវត្តតាមលក្ខណវិនិច្ឆ័យសម្រាប់និយោជិតនិងប្រតិបត្តិករសត្តឃាតដ្ឋាន ឬប្រតិបត្តិករទីកន្លែងកែច្នៃបឋមផលិតផលសត្វ
- ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់ប្រតិបត្តិការក្នុងសត្តឃាតដ្ឋាន ឬក្នុងទីកន្លែងកែច្នៃបឋមផលិតផលសត្វស្ដីពី សុខុមាលភាពសត្វ អនាម័យ និងការការពារបរិស្ថាន
- ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់ប្រតិបត្តិការកែច្នៃបឋមផលិតផលសត្វ ការរក្សាទុកប្រព្រឹត្តិកម្ម ការកម្ទេចចោលកាកសំណល់ និងការចែកចាយសាច់
- ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសផ្សេងទៀតដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥២.-**

ការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតផលសត្វត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៣.-**

សាច់ ផលិតផលសត្វ ឬផលិតផលសាច់ ដែលត្រូវបានត្រួតពិនិត្យអនាម័យ ត្រូវអនុលោមតាមបមាណីយសាច់ បមាណីយអនាម័យសាច់ ផលិតផលសត្វ ឬផលិតផលសាច់ និងបមាណីយសំណល់សារធាតុគីមី ជីវសាស្ត្រ និងវត្ថុមានសារធាតុវិទ្យុសកម្មក្នុងសាច់ ផលិតផលសត្វ ឬផលិតផលសាច់ទាំងនោះ ។

បមាណីយសាច់ បមាណីយអនាម័យសាច់ ផលិតផលសត្វ ឬផលិតផលសាច់ និងបមាណីយសំណល់សារធាតុគីមី ជីវសាស្ត្រ និងវត្ថុមានសារធាតុវិទ្យុសកម្មក្នុងសាច់ ផលិតផលសត្វ ឬផលិតផលសាច់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៤.-**

ចំពោះរាល់សត្វដែលនាំមកដល់សត្តឃាតដ្ឋានសម្រាប់ត្រៀមពិឃាតត្រូវ ៖

- មានវិញ្ញាបនបត្របសុព្យាបាល ឯកសារបញ្ជាក់អត្តសញ្ញាណសត្វ និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលត្រូវត្រួតពិនិត្យ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

- រក្សាសត្វទុកនៅកន្លែងបង្ខាំងសត្វក្នុងបរិវេណសត្តឃាតដ្ឋានក្នុងរយៈពេលពី ១២ (ដប់ពីរ) ទៅ ២៤ (ម្ភៃបួន) ម៉ោងមុនពេលពិឃាត

- ពិនិត្យសុខភាពសត្វ ។

### មាត្រា ៥៥.-

រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលចេញពីសត្តឃាតដ្ឋានត្រូវអ៊ូសត្រា ឬបោះត្រា ឬបិទស្លាកបសុព្យាបាលសម្គាល់ដោយមន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចទទួលខុសត្រូវសត្តឃាតដ្ឋាន ។

រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់កែច្នៃនៅទីកន្លែងកែច្នៃបឋមគ្រប់ប្រភេទ ត្រូវមានស្នាមត្រា ឬមានស្លាកបសុព្យាបាលសម្គាល់ ។

ការបង្កើត និងការប្រើប្រាស់ត្រា ឬស្លាកបសុព្យាបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ៥៦.-

រាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដែលដាក់តាំងលក់នៅតាមកន្លែងតាំងលក់ ឬនៅទីកន្លែងកែច្នៃបឋមគ្រប់ប្រភេទត្រូវមានស្នាមត្រា ឬស្លាកបសុព្យាបាលសម្គាល់ ។

### មាត្រា ៥៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសន្និធិ តាំងលក់ កែច្នៃ និងដឹកជញ្ជូនរាល់ផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ដើម្បីធ្វើអាជីវកម្មត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។

បទដ្ឋានបច្ចេកទេសបសុព្យាបាលក្នុងការធ្វើសន្និធិ ការតាំងលក់ ការកែច្នៃ និងការដឹកជញ្ជូនសាច់ និងផលិតផលសត្វ ដើម្បីធ្វើអាជីវកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៩
## ចរាចរណ៍សត្វ និងផលិតផលសត្វ

### មាត្រា ៥៨.-

ចរាចរណ៍សត្វ និងផលិតផលសត្វ ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិញ្ញាបនបត្របសុព្យាបាល និងការអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។ ចំពោះចរាចរណ៍សត្វ និងផលិតផលសត្វក្នុងផ្ទៃប្រទេសមិនតម្រូវឲ្យមានលិខិតអនុញ្ញាតទេ ប៉ុន្តែត្រូវមានវិញ្ញាបនបត្របសុព្យាបាល និងការអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។

**មាត្រា ៥៩.-**

ការនាំចូល ការនាំចេញ និងការនាំឆ្លងកាត់សត្វ និងផលិតផលសត្វ ត្រូវឆ្លងការត្រួតពិនិត្យអនាម័យ និងវិធានការបសុព្យាបាលរបស់មន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចប្រចាំការនៅកន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៦០.-**

ចំពោះការនាំចូលសត្វ ឬផលិតផលសត្វ ត្រូវមានវិញ្ញាបនបត្របសុព្យាបាល ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសនាំចេញ និងគោរពតាមបទដ្ឋានបច្ចេកទេសនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦១.-**

ចំពោះការនាំចេញសត្វ ឬផលិតផលសត្វ ត្រូវមានវិញ្ញាបនបត្របសុព្យាបាល ដែលចេញដោយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវគោរពតាមបទដ្ឋានបច្ចេកទេសនៃប្រទេសនាំចូល ។

**មាត្រា ៦២.-**

ចំពោះការនាំឆ្លងកាត់សត្វ ឬផលិតផលសត្វ ត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ។

**មាត្រា ៦៣.-**

ក្នុងករណីមានហានិភ័យ រាល់ចរាចរណ៍សត្វ ឬផលិតផលសត្វ ត្រូវបានដាក់ និងដកកំហិត ឬត្រូវហាមឃាត់ដោយផ្អែកលើមូលដ្ឋាននៃការវិភាគហានិភ័យ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការជូនដំណឹងអំពីការដាក់ និងដកកំហិត ឬការហាមឃាត់ខាងលើនេះ ។

**មាត្រា ៦៤.-**

នីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ចំពោះផលិតផលស៊ុត និងផលិតផលទឹកដោះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១០
## ស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ

### មាត្រា ៦៥.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់ទីតាំងសម្រាប់បង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

### មាត្រា ៦៦.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់សេវាកម្មក្នុងការអនុវត្តវិធានការបសុព្យាបាលចំពោះស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ។

### មាត្រា ៦៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលអាចបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ បានតែត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវចុះបញ្ជីស្ថានីយចត្តាឡីស័កនោះ ព្រមទាំងត្រូវអនុវត្តតាមការតម្រូវបទដ្ឋានបច្ចេកទេស ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ក្រោមការត្រួតពិនិត្យរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

នីតិវិធី និងការតម្រូវបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១១
## សុខុមាលភាពសត្វ

### មាត្រា ៦៨.-

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលកាន់កាប់សត្វសម្រាប់គ្រប់គោលបំណងលើកលែងលក្ខណៈប្រពៃណី និងលក្ខណៈគ្រួសារ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វដូចខាងក្រោម ៖

- ការកម្រិតទម្ងន់ផ្ទុកសម្រាប់សត្វពលកម្ម
- ការដឹកជញ្ជូនសត្វ
- ការពិឃាតសត្វ
- ការរៀបចំសាងសង់ទ្រុង ឬក្រោល
- ការចិញ្ចឹម និងការប្រើប្រាស់សត្វសម្រាប់មន្ទីរពិសោធន៍សត្វ សម្រាប់ពលកម្ម និងសត្វសម្រាប់គោលបំណងផ្សេងទៀត

- ការហាមការប្រើប្រាស់ឱសថសណ្តំ ឬធ្វើឲ្យសត្វសន្លប់ ឬការធ្វើទារុណកម្មផ្សេងទៀតក្នុងពេលដឹកជញ្ជូនដើម្បីធ្វើពាណិជ្ជកម្ម ឬដើម្បីធ្វើម្ហូបអាហារ

- បទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងសុខុមាលភាពសត្វផ្សេងទៀត ។

បទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៦៩.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវ ៖

- ជំរុញសកម្មភាពអប់រំ និងផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់អំពើទារុណលើសត្វ និងការលើកកម្ពស់ការអនុវត្តឲ្យស្របតាមបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ

- តាមដានត្រួតពិនិត្យលើការអនុវត្តបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ និងចាត់វិធានការចំពោះអំពើទារុណលើសត្វ

- សម្របសម្រួល និងចាត់ចែងដើម្បីចាប់ឃាត់ទុកសត្វ ដែលរងទារុណកម្ម ឬរងគ្រោះថ្នាក់ ។ ក្នុងករណីចាំបាច់ ត្រូវធ្វើការចាក់ថ្នាំការពារ ព្យាបាល ឬថែទាំរក្សាទុកសត្វ ដែលការចំណាយជាបន្ទុករបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាម្ចាស់ ឬអ្នកកាន់កាប់សត្វ ។ ករណីអត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់សត្វមិនត្រូវបានស្គាល់ រាល់ការចំណាយជាបន្ទុករបស់រដ្ឋ ។

# ជំពូកទី ១២

# ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និង ទីកន្លែងអាជីវកម្មសត្វ

## មាត្រា ៧០.-

ការបង្កើតទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវគោរពតាមបទដ្ឋានបច្ចេកទេសដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ។ ចំពោះទីកន្លែងព្យាបាលសត្វ ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ ដែលជាសមាជិកគណៈបសុពេទ្យ ។

## មាត្រា ៧១.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចត្រួតពិនិត្យ និងផ្តល់សេវាកម្មក្នុងការអនុវត្តវិធានការបសុព្យាបាល ចំពោះទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ ។

## មាត្រា ៧២.-

នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

# ជំពូកទី ១៣
# វិជ្ជាជីវៈបសុព្យាបាល
## ផ្នែកទី ១
## គណៈបសុពេទ្យ

## មាត្រា ៧៣.-

ត្រូវបង្កើតគណៈបសុពេទ្យ ដើម្បីលើកកម្ពស់ការចូលរួមរបស់បសុពេទ្យ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈបសុព្យាបាល ស្របតាមក្រមសីលធម៌វិជ្ជាជីវៈបសុព្យាបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ផ្នែកទី ២
## អ្នកបច្ចេកទេសបសុពេទ្យ និងភ្នាក់ងារបសុពេទ្យ

## មាត្រា ៧៤.-

អ្នកបច្ចេកទេសបសុពេទ្យ និងភ្នាក់ងារបសុពេទ្យអាចប្រកបវិជ្ជាជីវៈបសុព្យាបាលបានលុះត្រាតែមានបសុពេទ្យម្នាក់ ដែលទទួលស្គាល់ដោយគណៈបសុពេទ្យជាអ្នកទទួលខុសត្រូវ ។

## ផ្នែកទី ៣
## ភ្នាក់ងារសុខភាពសត្វភូមិ

## មាត្រា ៧៥.-

ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាយន្តការកម្រិតមូលដ្ឋានក្នុងគោលបំណងឲ្យមានការរួមចំណែកបំពេញបន្ថែមតម្រូវការ និងការលើកកម្ពស់គុណភាពសេវាកម្មក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅមូលដ្ឋាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

### មាត្រា ៧៦.-

ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវបានជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋានសាមី ដើម្បីមកទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### មាត្រា ៧៧.-

ភ្នាក់ងារសុខភាពសត្វភូមិមិនមែនជាភ្នាក់ងារក្របខ័ណ្ឌរដ្ឋទេ ប៉ុន្តែជាភ្នាក់ងារស្ម័គ្រចិត្តជំនួយបម្រើសេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ ។

ភ្នាក់ងារសុខភាពសត្វភូមិ អាចប្រកបវិជ្ជាជីវៈបសុព្យាបាលបានលុះត្រាតែមានបសុពេទ្យម្នាក់ ជាអ្នកទទួលខុសត្រូវ ។

### មាត្រា ៧៨.-

ការជ្រើសរើស ការបណ្តុះបណ្តាល ការគ្រប់គ្រងឲ្យមាននិរន្តរភាព និងការកិច្ចភ្នាក់ងារសុខភាពសត្វភូមិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១៤
## មន្ទីរពិសោធន៍

### មាត្រា ៧៩.-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់មន្ទីរពិសោធន៍រដ្ឋ និងឯកជនដែលមានលក្ខណៈគ្រប់គ្រាន់ជាមន្ទីរពិសោធន៍យោងដើម្បី ៖

- ត្រួតពិនិត្យបណ្តាញការងារធ្វើរោគវិនិច្ឆ័យបសុព្យាបាល
- ត្រួតពិនិត្យបណ្តាញការងារធ្វើវិភាគចំណីសត្វ បសុឱសថ សេនេទិកសត្វ និងការធ្វើវិភាគផ្សេងទៀតក្នុងផលិតកម្មសត្វ
- ត្រួតពិនិត្យការអនុវត្តវិធីសាស្ត្រយោង ។

### មាត្រា ៨០.-

មន្ទីរពិសោធន៍រដ្ឋ និងឯកជនសម្រាប់សុខភាពសត្វ និងផលិតកម្មសត្វ ដែលត្រូវបានកំណត់ជាមន្ទីរពិសោធន៍យោង ត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងកិច្ចប្រតិបត្តិការដូចខាងក្រោម ៖

- អនុវត្តវិធីសាស្ត្រយោង
- អនុវត្តតួនាទី និងសិទ្ធិរបស់មន្ទីរពិសោធន៍
- អនុវត្តការចុះបញ្ជីរអោក់ទីហ្វ

ROYAUME DU CAMBODGE
ព្រះរាជវាំង
LE MINISTRE DU PALAIS ROYAL

- តាមដាន ធ្វើសវនកម្ម ដើម្បីធានាគុណភាពមន្ទីរពិសោធន៍ ។

គោលការណ៍ណែនាំប្រតិបត្តិរបស់មន្ទីរពិសោធន៍សម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៨១.-**

កិច្ចប្រតិបត្តិការរបស់មន្ទីរពិសោធន៍រដ្ឋ និងឯកជនសម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធី និងការតម្រូវសម្រាប់ការទទួលស្គាល់កិច្ចប្រតិបត្តិការរបស់មន្ទីរពិសោធន៍រដ្ឋ និងឯកជន សម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១៥
## ការស្រាវជ្រាវវិស័យ
## សុខភាពសត្វ និងផលិតកម្មសត្វ

**មាត្រា ៨២.-**

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវសិក្សារៀបចំកម្មវិធីស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សំដៅលើកកម្ពស់ចំណេះដឹងទាំងផ្នែកទ្រឹស្ដី ទាំងផ្នែកអនុវត្តន៍ ដើម្បីផលប្រយោជន៍សាធារណៈ ផលប្រយោជន៍វិទ្យាសាស្ត្រ និងការអភិវឌ្ឍ ។

**មាត្រា ៨៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើកម្មវិធីស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្ដុះបណ្ដាលវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

**មាត្រា ៨៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតគ្រឹះស្ថានស្រាវជ្រាវឯកជន ឬគ្រឹះស្ថានបណ្ដុះបណ្ដាលឯកជន ឬអ្នកស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ។

ការស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវអនុវត្តតាមពិធីសារស្រាវជ្រាវជាក់លាក់ និងតាមបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ ដែលកំណត់ដោយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

នីតិវិធីនៃការទទួលស្គាល់គ្រឹះស្ថានស្រាវជ្រាវឯកជន ឬគ្រឹះស្ថានបណ្តុះបណ្តាលឯកជន ឬអ្នកស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៨៥.-**

ការស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវមានមូលនិធិសម្រាប់ដំណើរការ ។

មូលនិធិសម្រាប់ការស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ អាចមានប្រភពមកពី ៖

- ថវិកាជាតិដែលជាកញ្ចប់ដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ហិរញ្ញប្បទានដែលបានមកពីដៃគូអភិវឌ្ឍ
- ប្រភពផ្សេងទៀត ។

ការបង្កើតមូលនិធិសម្រាប់ការស្រាវជ្រាវខាងសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ១៦
## ការចុះបញ្ជី

**មាត្រា ៨៦.-**

រាល់ការចុះបញ្ជី ត្រូវឆ្លើយតបក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលពាក្យស្នើសុំ ដែលបានបំពេញ និងភ្ជាប់ឯកសារគ្រប់គ្រាន់នៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

**មាត្រា ៨៧.-**

នីតិវិធីនៃការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១៧
## ភារកិច្ចអ្នកកាន់លិខិតអនុញ្ញាត

**មាត្រា ៨៨.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្ម ឬធ្វើសេវាកម្មគ្រប់រូបភាពដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វក្រោមបទប្បញ្ញត្តិនៃច្បាប់នេះមានភារកិច្ចដូចខាងក្រោម ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- ត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រសម្រាប់ប្រតិបត្តិការដែលពាក់ព័ន្ធនៅក្នុងគ្រឹះស្ថាន ឬទីកន្លែងអាជីវកម្មរបស់ខ្លួន

- ត្រូវរាយការណ៍ ឬផ្តល់ព័ត៌មានជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ចនៅក្នុងមូលដ្ឋានសាមី អំពីគ្រោះថ្នាក់ ឬផលប៉ះពាល់ដែលបង្កដោយសត្វ ផលិតផលសត្វ ចំណីសត្វ ឬបសុឱសថគ្រប់ប្រភេទ

- ត្រូវប្រកាសអំពីប្រភេទ យថាប្រភេទ បរិមាណសត្វ និងផលិតផលសត្វ ដែលធ្វើអាជីវកម្ម ឬធ្វើសេវាកម្ម និងបសុឱសថ ឬចំណីសត្វគ្រប់ប្រភេទដែលធ្វើអាជីវកម្ម ពាណិជ្ជកម្ម ផលិត ឬធ្វើការលាយផ្សំ និងត្រូវមានកំណត់ត្រាព័ត៌មានចុះក្នុងសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធ

- ត្រូវរក្សាស្ថានភាពអនាម័យនៅទីកន្លែងផលិតកម្ម និងអាជីវកម្ម

- ត្រូវនាំសត្វយកមកពិនិត្យនៅតាមទីតាំងដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណសត្វ និងវិញ្ញាបនបត្របសុព្យាបាល

- ក្នុងករណីដែលមិនបានបំពេញតាមការតម្រូវបមាណីយ ឬតាមបទដ្ឋានបច្ចេកទេស ដែលបានកំណត់ ឬមានហានិភ័យប៉ះពាល់ដល់សុខភាពសត្វ មនុស្ស និងបរិស្ថាន ត្រូវប្រមូលនាំយកសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វមករក្សាទុក ដើម្បីទប់ស្កាត់ហានិភ័យតាមការចាំបាច់ និងទទួលខុសត្រូវលើការចំណាយទាំងនោះ

- បំពេញកាតព្វកិច្ចផ្សេងៗទៀត ដែលមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវកំណត់គំរូសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ ។

## មាត្រា ៨៩.-

ការបោះពុម្ពផ្សាយ ឬការផ្សាយពាណិជ្ជកម្មអំពីពូជសត្វ សត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ ត្រូវមានខ្លឹមសារស្របនឹងខ្លឹមសារដែលបានចុះបញ្ជី ឬស្របនឹងបច្ចេកទេសជាក់លាក់ ហើយមានសង្គតិភាពទៅនឹងទិន្នន័យព័ត៌មានបច្ចេកទេសរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

## មាត្រា ៩០.-

គ្រឹះស្ថាននាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មីនូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំចំណីសត្វ ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ ដែលជាសមាជិកគណៈបសុពេទ្យ ។

អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំលក់រាយចំណីសត្វ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំវិជ្ជាជីវៈ ដែលចេញដោយមន្ត្រីខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវផ្តល់សេវាកម្មក្នុងការអនុវត្តកម្មវិធីអប់រំវិជ្ជាជីវៈដល់អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំលក់រាយបសុឱសថ ចំណីសត្វ សត្វ និងផលិតផលសត្វ ។

**មាត្រា ៩១.-**

គ្រឹះស្ថាននាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ផ្គត់ផ្គង់ចែកចាយនូវបសុឱសថ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបុគ្គលិកទទួលខុសត្រូវយ៉ាងតិចម្នាក់ដែលជាសមាជិកគណៈបសុពេទ្យ ។ សម្រាប់គ្រឹះស្ថានផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ ត្រូវមានបន្ថែមបសុឱសថការី ឬឱសថការីទទួលខុសត្រូវម្នាក់ ឬច្រើននាក់ដែលបានបំពេញតាមនីតិវិធីច្បាប់ជាធរមាន ។

អ្នកផ្គត់ផ្គង់ចែកចាយ ឬអ្នកលក់ដុំលក់រាយបសុឱសថ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំវិជ្ជាជីវៈ ជាលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

**មាត្រា ៩២.-**

បសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំបសុឱសថ ឬចំណីសត្វដែលអនុញ្ញាតឲ្យនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី អាចមានសុពលភាពផ្គត់ផ្គង់ ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាតែត្រូវបានធ្វើប្រតិវេទន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការត្រួតពិនិត្យដោយអនុលោមតាមនីតិវិធីនៃច្បាប់នេះ ។

នីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៩៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ វិភាគ សាកល្បង ការទទួលស្គាល់នៅក្នុងគ្រប់សកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ឬធ្វើសេវាកម្មពាក់ព័ន្ធនឹងសត្វ និងផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ មានកាតព្វកិច្ចបង់កម្រៃសេវាកម្ម ។

កម្រៃសេវាកម្មតាមប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# ជំពូកទី ១៨
# ការត្រួតពិនិត្យអនាម័យ

## មាត្រា ៩៤.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលត្រូវធ្វើការត្រួតពិនិត្យអនាម័យដូចខាងក្រោម ៖

- កន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល
- ស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ
- ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
- ទីកន្លែងព្យាបាលសត្វ ផ្សារសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ
- មធ្យោបាយដឹកជញ្ជូនសត្វ ផលិតផលសត្វ ផលិតផលសាច់ បសុឱសថ ចំណីសត្វ ឧបករណ៍ និងសម្ភារបរិក្ខារបសុព្យាបាល
- គ្រឹះស្ថានអាជីវកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម និងទីកន្លែងផ្សេងទៀតដែលរូបជាតុសេនេទិកសត្វ ចំណីសត្វ និងបសុឱសថ ត្រូវបានរក្សាទុក ឬលក់ចែកចាយ
- កន្លែងតាំងលក់ផលិតផលសត្វ និងផលិតផលសាច់ និងទីកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានហានិភ័យ ឬសង្ស័យមានហានិភ័យបណ្តាលមកពីការឆ្លងរាលដាលជំងឺសត្វ ដោយសហការជាមួយអង្គភាពនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

## មាត្រា ៩៥.-

ម្ចាស់ ឬអ្នកកាន់កាប់សត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចដើម្បីសម្រួលការត្រួតពិនិត្យអនាម័យ និងការអនុវត្តវិធានការបសុព្យាបាល ។

ចំណាយលើការអនុវត្តវិធានការបសុព្យាបាលដូចជា វិធានការទុកព្យាបាល ចាក់ថ្នាំការពារ រំងាប់មេរោគ ឃាត់ទុក ថែរក្សា ឬបំផ្លាញចោលជាដើម ជាបន្ទុករបស់ម្ចាស់ ឬអ្នកកាន់កាប់ ។ ក្នុងករណីមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់ ការចំណាយជាបន្ទុករបស់រដ្ឋ ។

## មាត្រា ៩៦.-

នីតិវិធីនៃការត្រួតពិនិត្យអនាម័យបសុព្យាបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ១៩
# អធិការកិច្ច

**មាត្រា ៩៧.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់គុណវុឌ្ឍិ និងតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីបំពេញភារកិច្ច និងទទួលខុសត្រូវចំពោះគ្រប់សកម្មភាពពាក់ព័ន្ធក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

ក្នុងករណីសង្ស័យមានភាពមិនប្រក្រតី ឬសង្ស័យមានបទល្មើសពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ សុខុមាលភាពសត្វ បសុឱសថ និងចំណីសត្វ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះនៅក្នុងដែនសមត្ថកិច្ចសាមី ដើម្បីបង្ការ ទប់ស្កាត់ លុបបំបាត់ហានិភ័យនៃជំងឺសត្វ និងបង្ក្រាបបទល្មើសនៅតាម ៖

- កន្លែង ឬស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែនដែលកំណត់ដោយរាជរដ្ឋាភិបាល
- ស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
- ទីកន្លែងព្យាបាលសត្វ ផ្សារសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងកន្លែងតាំងលក់
- គ្រឹះស្ថានអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម ទីកន្លែងតាំងលក់ និងទីកន្លែងផ្សេងទៀត ដែលរូបធាតុសេនេទិកសត្វ ចំណីសត្វ បសុឱសថ និងផលិតផលសត្វ ត្រូវបានរក្សាទុក ឬលក់ចែកចាយ
- គ្រឹះស្ថានស្រាវជ្រាវ មន្ទីរពិសោធន៍ ស្ថានីយពិសោធន៍
- ទីកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានហានិភ័យ ឬសង្ស័យថាមានហានិភ័យបណ្តាលមកពីការឆ្លងរាលដាលជំងឺសត្វ ឬសង្ស័យថាមានបទល្មើសពាក់ព័ន្ធនៃច្បាប់នេះ ។

ក្នុងពេលអនុវត្តមុខការ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានភារកិច្ច និងសិទ្ធិដូចខាងក្រោម ៖

- តម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងសត្វ ឬផលិតផលសត្វ ផ្តល់ព័ត៌មាន និងបង្ហាញលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធក្នុងសកម្មភាពរបស់ខ្លួន
- ដកយកសំណាក វត្ថុវិភាគរបស់សត្វ ផលិតផលសត្វ ចំណីសត្វ សារធាតុបន្ថែម បសុឱសថ ឬវត្ថុធាតុដើមនៃផលិតផលទាំងនេះ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងធ្វើការវិភាគភ្នាក់ងារបង្កជំងឺ ឬធ្វើការវិភាគផ្ទៀងផ្ទាត់បមាណីយដើម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

- ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារដែលពាក់ព័ន្ធ ក្នុងករណីដែលអ្នកកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រនោះ ប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាង និងកសាងសំណុំរឿងនៃបទល្មើសស្របតាមនីតិវិធី
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ ។

**មាត្រា ៩៨.-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវមានលិខិតបញ្ជាបេសកកម្ម ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិ ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩៩.-**

មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

បែបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទាដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១០០.-**

មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ អង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

ក្នុងករណីបានជួបប្រទះបទល្មើសជាក់ស្ដែង មន្ត្រីនៃអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី ។

ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងការត្រួតពិនិត្យបទល្មើស ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១០១.-**

ការកសាងសំណុំរឿងបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

គំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១០២.-**

នៅក្នុងដំណើរការអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងករណីមានភស្តុតាងជាក់ស្តែងបញ្ជាក់អំពីការប្រព្រឹត្តល្មើសនឹងច្បាប់នេះ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ មានសិទ្ធិតម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវលើប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងបទល្មើសផ្អាករាល់សកម្មភាពជាបណ្តោះអាសន្នឬទាំងស្រុង ។

**មាត្រា ១០៣.-**

បុគ្គលណាដែលមិនសុខចិត្តនឹងវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ច មានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្មនិងបសុពេទ្យ-បាលដើម្បីដោះស្រាយ ។ ក្នុងករណីមិនសុខចិត្ត បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃទទួលសេចក្តីសម្រេច ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង ។

ក្នុងករណីដែលបុគ្គលនោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី ។

**មាត្រា ១០៤.-**

ក្នុងករណីដែលវត្ថុតាងមិនអាចរក្សាទុកបានយូរដែលបណ្តាលមកពីភាពស្អុយរលួយ ធ្វើឲ្យបាត់បង់បរិមាណ គុណភាព ហួសពេលកំណត់ប្រើប្រាស់ ពុកផុយ ឬចម្លងមេរោគ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វត្រូវស្នើសុំការសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោល ឬលក់វត្ថុតាងទាំងនោះតាមនីតិវិធីជាធរមាន ។

ការចំណាយលើវត្ថុវិភាគនិងសេវាកម្មវិភាគ ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់នេះជាបន្ទុករបស់ម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស ។

ក្នុងករណីមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស រាល់ការចំណាយជាបន្ទុករបស់រដ្ឋ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ២០
# ទោសប្បញ្ញត្តិ

## មាត្រា ១០៥.-

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរការដកហូត ឬការព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ ។

## មាត្រា ១០៦.-

ការព្រមានជាលាយលក្ខណ៍អក្សរការដកហូត ឬការព្យួរវិញ្ញាបនបត្រ និងលិខិតអនុញ្ញាតគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលដែលមានសមត្ថកិច្ចចេញវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

## មាត្រា ១០៧.-

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងមាត្រា ១១០ មាត្រា ១១១ មាត្រា ១១២ និងមាត្រា ១១៣ នៃច្បាប់នេះ ។

ការពិន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវចងក្រងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី ។

ក្នុងករណីមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ចដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលតាមវិធានការបសុព្យាបាល ។

នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ១០៨.-

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ១០៩.-**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតពាក់ព័ន្ធចំពោះបុគ្គលកាន់កាប់សត្វបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- មិនជូនដំណឹងបន្ទាន់មកអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនៅពេលសង្ស័យថាមានសត្វកើតជំងឺឆ្លង ឬមានសត្វស្លាប់ដោយជំងឺវិញ្ញត្តិ ។

២- ពុំព្រមឆ្លើយសំណួរ ឬផ្តល់ឯកសារដែលតម្រូវដោយមន្ត្រីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច ។

៣- បដិសេធ ឬមិនបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វ និងការប្រមូលវត្ថុវិភាគសម្រាប់ធ្វើការវិភាគ ។

៤- មិនអនុវត្តវិធានការអនាម័យសត្វ និងអនាម័យផលិតផលសត្វ ដែលតម្រូវដោយបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ ។

៥- ប្រព្រឹត្តអំពើណាមួយដែលបង្កទារុណកម្ម បង្កឲ្យសត្វឈឺចាប់ ឬស្តែងចេញនូវភាពអណោចអធម្ម ផ្ទុយពីបទដ្ឋានបច្ចេកទេសសុខុមាលភាពសត្វ ។

៦- ចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មដោយគ្មានអត្តសញ្ញាណសម្គាល់ ។

**មាត្រា ១១០.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ១០០ ០០០ (មួយសែន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- មិនធ្វើអនាម័យសត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់សាច់ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ ទីកន្លែងចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយបសុឱសថ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយចំណីសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ ។

២- មិនអនុវត្តតាមលក្ខខណ្ឌដែលភ្ជាប់កាតព្វកិច្ចក្នុងការកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយដែលពាក់ព័ន្ធនឹងសត្វ និងផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងចំណុច ១ ដល់ចំណុច ៥ កថាខណ្ឌទី ១ មាត្រា ៨៨ នៃច្បាប់នេះ ។

៣- មិនអនុវត្តតាមបទប្បញ្ញត្តិហាមឃាត់នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ត្រួតពិនិត្យជំងឺសត្វក្នុងការធ្វើចរាចរណ៍សត្វ និងផលិតផលសត្វដែលធ្វើឲ្យរាលដាលជំងឺឆ្លងសត្វ ។

៤- មិនចូលរួមអនុវត្តវិធានការបសុព្យាបាលទប់ស្កាត់ជំងឺឆ្លងសត្វ នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ត្រួតពិនិត្យជំងឺសត្វ តាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

៥- មិនចូលរួមអនុវត្តការសម្អាត ការកម្ចាត់មេរោគចំពោះអគារ ឧបករណ៍ សម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូននៅក្នុងតំបន់ឆ្លងជំងឺសត្វ តាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

## មាត្រា ១១១.-

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ៤ ០០០ ០០០ (បួនលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- លក់ដុំ លក់រាយបសុឱសថ ឬចំណីសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

២- មិនអនុវត្តតាមកាតព្វកិច្ចអ្នកកាន់លិខិតអនុញ្ញាតដូចមានចែងក្នុងចំណុច ៦ កថាខណ្ឌទី ១ មាត្រា ៨៨ នៃច្បាប់នេះ ។

៣- គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវក្នុងគ្រឹះស្ថាននាំចូល នាំចេញ ផលិត ឬលាយផ្សំ វេចខ្ចប់ជាថ្មីនូវចំណីសត្វ ដូចមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៩០ នៃច្បាប់នេះ ។

៤- គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវក្នុងគ្រឹះស្ថានពាណិជ្ជកម្ម ផលិត ឬលាយផ្សំ វេចខ្ចប់ជាថ្មីបសុឱសថ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ មាត្រា ៩១ នៃច្បាប់នេះ ។

៥- គ្មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវ នៅកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មខ្នាតធំ និងខ្នាតមធ្យមដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ ។

៦- គ្មានបុគ្គលិកបច្ចេកទេសបសុព្យាបាលទទួលខុសត្រូវក្នុងទីកន្លែងព្យាបាលសត្វ ដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់នេះ ។

៧- មិនធ្វើប្រតិវេទន៍សម្រាប់ការត្រួតពិនិត្យ ចំពោះបសុឱសថ ឬចំណីសត្វដែលនាំចូល នាំចេញ ផលិត ឬលាយផ្សំនៅមុនពេលផ្គត់ផ្គង់ចែកចាយ ។

៨- ធ្លាប់បានទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ១០៩ នៃច្បាប់នេះ ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ហើយនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

## មាត្រា ១១២.-

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ៧០០០ ០០០ (ប្រាំពីរលាន) រៀល ចំពោះបុគ្គលណាដែលធ្វើពាណិជ្ជកម្ម និងអាជីវកម្មសត្វ ផលិតផលសត្វ បសុឱសថ ចំណីសត្វ ប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- បោះបង់ចោល លែងចោល ពិឃាតយកសាច់ធ្វើជាអាហារ ដើម្បីយកផលិតផលធ្វើជាអាហារ លក់ដូរ កែច្នៃ ឬចែកចាយដល់សាធារណជន ឬធ្វើចរាចរណ៍សត្វ ឬផលិតផលសត្វដែលមានជំងឺ ឬសង្ស័យថា [illegible]

២- លក់ដុំ លក់រាយ នូវសាច់សត្វ ឬផលិតផលសត្វដែលផ្ទុកសំណល់សារធាតុគីមីលើសកម្រិតបមាណីយ ។

៣- សាងសង់សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់សាច់ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ ទីកន្លែងចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយបសុឱសថ ទីកន្លែងផលិតលាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយចំណីសត្វ ទីកន្លែងប្រមូលផ្ដុំរក្សាសត្វ និងស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វខុសពីទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាត ។

៤- ធ្វើសន្និធិ ឬលក់ចែកចាយសាច់សត្វ ឬផលិតផលសត្វដោយគ្មានត្រា ឬស្លាកបសុព្យាបាលសម្គាល់ ។

៥- មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់បសុឱសថ ឬចំណីសត្វ ។

៦- មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ។

៧- មិនអនុវត្តតាមបទដ្ឋានបច្ចេកទេស និងវិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការនៃការផលិត ឬការលាយផ្សំបសុឱសថ ឬចំណីសត្វ ។

៨- ផ្គត់ផ្គង់ ចែកចាយ ឬដឹកជញ្ជូនចល័តលក់ដោយផ្ទាល់ដល់អ្នកប្រើប្រាស់បសុឱសថ ឬចំណីសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

៩- លក់ដុំ លក់រាយបសុឱសថ ឬចំណីសត្វខុសការកំណត់ក្នុងលិខិតអនុញ្ញាតនាំចូល ។

១០- ចិញ្ចឹមសត្វឬបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាត និងមិនបានចុះបញ្ជីកសិដ្ឋានស្របតាមច្បាប់នេះ ។

១១- នាំចូល នាំចេញ ឬផ្គត់ផ្គង់ចែកចាយសត្វ បង្កាត់ពូជ ឬរូបធាតុសេនេទិកសត្វគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

១២- ធ្វើពាណិជ្ជកម្មបសុឱសថ ឬចំណីសត្វ ដែលជាផលិតផលមិនអនុវត្តតាមការតម្រូវបមាណីយ ឬផុតសុពលភាពប្រើប្រាស់ដែលបានកំណត់លើស្លាកសញ្ញាព័ត៌មាន ។

១៣- ធ្វើសេវាកម្មដោយបំពេញមុខងារជាបសុពេទ្យដោយគ្មានការចុះបញ្ជី ឬគ្មានវិញ្ញាបនបត្រទទួលស្គាល់ដោយគណៈបសុពេទ្យ ។

១៤- ផ្សាយពាណិជ្ជកម្មស្ដីពីបសុឱសថ ឬចំណីសត្វដោយល្មើសនឹងមាត្រា ៨៩ នៃច្បាប់នេះ ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្ដងរួចហើយ ហើយនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

ROYAUME DU CAMBODGE · LE GREFFE DU PALAIS ROYAL
ក្រាបបង្គំជូនចាប់

**មាត្រា ១១៣.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល ចំពោះបុគ្គលណាដែលធ្វើពាណិជ្ជកម្ម និងអាជីវកម្មដោយប្រព្រឹត្តអំពើណាមួយ ដូចខាងក្រោម ៖

១- បង្កើតទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ និងស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វគ្មានលិខិតអនុញ្ញាត ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។

២- បង្កើតសត្តឃាតដ្ឋាន ធ្វើអាជីវកម្មពិឃាតសត្វ និងបង្កើតទីកន្លែងកែច្នៃបឋមផលិតផលសត្វគ្មានលិខិតអនុញ្ញាត ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។

៣- នាំចូល នាំចេញពូជសត្វ ផលិតពូជសត្វ ឬបង្កើតពូជថ្មីនៃសត្វមិនបានចុះបញ្ជី ឬគ្មានវិញ្ញាបនបត្របញ្ជាក់ពូជសត្វ ឬពូជថ្មីនៃសត្វនោះ ។

៤- នាំចូល នាំចេញ លាយផ្សំ វេចខ្ចប់ជាថ្មី ធ្វើសន្និធិបសុឱសថ ឬចំណីសត្វគ្មានវិញ្ញាបនបត្របញ្ជាក់បញ្ជិកា ឬមិនបានចុះបញ្ជីជាថ្មី ឬគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ។

៥- នាំចូល នាំចេញ និងចរាចរបសុឱសថ ឬចំណីសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៧ និងមាត្រា ៤៧ នៃច្បាប់នេះ ។

៦- នាំចូល នាំឆ្លងកាត់សត្វ ឬផលិតផលសត្វតាមច្រកផ្សេងខុសការកំណត់របស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

៧- នាំចូល នាំចេញសត្វ ឬផលិតផលសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់នេះ ឬមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល ។

៨- នាំចូលសត្វ ឬផលិតផលសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៦០ នៃច្បាប់នេះ ។

៩- នាំចេញសត្វ ឬផលិតផលសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៦១ នៃច្បាប់នេះ ។

១០- នាំឆ្លងកាត់សត្វ និងផលិតផលសត្វខុសលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៦២ នៃច្បាប់នេះ ។

១១- ចរាចរសត្វ ឬផលិតផលសត្វក្នុងផ្ទៃប្រទេសដោយមិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា ៥៨ នៃច្បាប់នេះ ។

១២- ធ្វើប្រតិបត្តិការមន្ទីរពិសោធន៍ ឬបង្កើតគ្រឹះស្ថានស្រាវជ្រាវឯកជនក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វដោយគ្មានការទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ហើយនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ១១៤.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- ក្លែងបន្លំស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ឬប្រើស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ចំពោះបសុឱសថ ឬចំណីសត្វ ។

២- ក្លែងបន្លំសំបកវេចខ្ចប់បសុឱសថ ឬចំណីសត្វ ។

៣- ក្លែងបន្លំឈ្មោះទូទៅ ឬឈ្មោះពាណិជ្ជកម្មបសុឱសថ ឬចំណីសត្វ ។

៤- ក្លែងបន្លំអត្តសញ្ញាណសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ ។

៥- ក្លែងបន្លំសមាសធាតុ ឬមានសមាសធាតុផ្សេងពីការអះអាងនៅពេលស្នើសុំការចុះបញ្ជី ឬជាបសុឱសថ ឬចំណីសត្វក្រៅបមាណីយ ឬខូចគុណភាព ។

៦- ក្លែងបន្លំប្រភពដើមបសុឱសថ ឬចំណីសត្វ ។

៧- ក្លែងបន្លំព័ត៌មានទិន្នន័យបមាណីយ និងបទដ្ឋានបច្ចេកទេសសម្រាប់ការចុះបញ្ជីបសុឱសថ ឬចំណីសត្វ ។

**មាត្រា ១១៥.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងត្រូវពិន័យជាប្រាក់ចំនួនពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- ធ្វើពាណិជ្ជកម្មគ្រប់រូបភាពនូវបសុឱសថព្រមទាំងវត្ថុធាតុដើម សារធាតុសកម្មសម្រាប់លាយផ្សំបសុឱសថដែលហាមឃាត់ ឬស្ថិតក្នុងបញ្ជីហាមឃាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើពាណិជ្ជកម្មគ្រប់រូបភាពនូវចំណីសត្វ ព្រមទាំងវត្ថុធាតុដើម សារធាតុបន្ថែមសម្រាប់ផលិតលាយផ្សំចំណីសត្វដែលហាមឃាត់ ឬស្ថិតក្នុងបញ្ជីហាមឃាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣- ធ្វើពាណិជ្ជកម្ម ផលិត លាយផ្សំបសុឱសថ ឬចំណីសត្វ ដោយប្រើសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ។

៤- ចិញ្ចឹមសត្វដោយល្មើសនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ។

៥- នាំចូលដោយចេតនានូវសត្វ ឬផលិតផលសត្វដែលមានជំងឺឆ្លង ឬផ្ទុកមេរោគបង្កជំងឺ ខូចគុណភាព ឬបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១១៦.-**

ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

១- ក្លែងលិខិតអនុញ្ញាត វិញ្ញាបនបត្រ លេខបញ្ជិកា ឬឯកសារបែបបទសម្រាប់គ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ ដូចមានចែងក្នុងច្បាប់នេះ ។

២- ក្លែងលទ្ធផលវិភាគគុណភាព និងសុវត្ថិភាពបសុឱសថ និងចំណីសត្វ ឬក្លែងលទ្ធផលសាកល្បងជីវប្រសិទ្ធភាពបសុឱសថ ឬប្រសិទ្ធភាពនៃចំណីសត្វ ។

៣- ក្លែងលទ្ធផលវិភាគ វត្ថុវិភាគ រោគវិនិច្ឆ័យជំងឺសត្វ ឬក្លែងលទ្ធផលវិភាគគុណភាព សំណល់សារធាតុគីមីនិងជីវៈសាស្ត្រនៅក្នុងសាច់សត្វ ផលិតផលសត្វ ។

៤- ក្លែងស្លាកសម្គាល់អត្តសញ្ញាណសត្វ ដែលប្រើសម្រាប់សម្គាល់សត្វ ។

៥- ក្លែងត្រា ឬស្លាកបសុព្យាបាលដែលប្រើសម្គាល់លើផ្ទាំងសាច់ សាច់ ឬកញ្ចប់ផលិតផលសត្វ ។

៦- បង្កឧបសគ្គតាមគ្រប់រូបភាពដល់កិច្ចអន្តរាគមន៍ទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វរបស់មន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច ក្នុងពេលបំពេញប្រតិបត្តិការស្របតាមច្បាប់នេះ ។

៧- គំរាមកំហែង ឬប្រតិកម្មតបដោយហិង្សាមកលើមន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ឬមន្ត្រីអន្តរាគមន៍មានសមត្ថកិច្ចទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វ ក្នុងពេលបំពេញប្រតិបត្តិការស្របតាមច្បាប់នេះ ។

៨- មិនព្រមប្រគល់ លាក់បំបាំង បំផ្លាញវត្ថុតាង ឬចាត់ចែងវត្ថុតាងដែលជាកម្មវត្ថុនៃការចាប់យកជាបណ្តោះអាសន្ន ឬត្រូវបានរឹបអូសស្របតាមច្បាប់នេះ ។

**មាត្រា ១១៧.-**

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបទល្មើសនៃមាត្រា ១១៤ មាត្រា ១១៥ និងមាត្រា ១១៦ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល និងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១១៨.-**

បុគ្គលដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា ១១៤ មាត្រា ១១៥ មាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ អាចត្រូវបានដកហូត ឬលុបចោលដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយប្រធានអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលនូវវិញ្ញាបនបត្រ និងលិខិតអនុញ្ញាតគ្រប់ប្រភេទពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើឲ្យមានផលប៉ះពាល់ ឬមានគ្រោះថ្នាក់ដល់បរិស្ថានឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ ត្រូវជួសជុលព្យសនកម្មតាមទំហំដែលធ្វើឲ្យប៉ះពាល់ ។

**មាត្រា ១១៩.-**

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ១១២ មាត្រា ១១៣ ដែលសំណុំរឿងបានបញ្ជូនមកតុលាការ និងបទល្មើសដូចមានចែងក្នុងមាត្រា ១១៤ មាត្រា ១១៥ និងមាត្រា ១១៦ នៃច្បាប់នេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស ៖

១- ហាមឃាត់ការប្រកបមុខរបរដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ ឬចំណីសត្វ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ឬជាស្ថាពរ ។

២- រឹបអូសវត្ថុតាងនៃបទល្មើស ។

៣- បិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

៤- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

**មាត្រា ១២០.-**

មន្ត្រីមានសមត្ថកិច្ចណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរារាំងការអនុវត្តច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

## ជំពូកទី ២១
## អន្តរប្បញ្ញត្តិ

**មាត្រា ១២១.-**

អនុក្រឹត្យ និងប្រកាសដែលកំពុងមានអានុភាពអនុវត្ត ត្រូវបន្តអនុវត្តត្រឹមទំហំដែលមិនផ្ទុយជាមួយនឹងច្បាប់នេះ រហូតដល់មានអនុក្រឹត្យ និងប្រកាសថ្មីមកជំនួស ។



**មាត្រា ១២២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតមានសុពលភាពមុនច្បាប់នេះចូលជាធរមាន ហើយនៅសល់សន្និធិ ឬកំពុងតាំងលក់សត្វ ផលិតផលសត្វ រូបធាតុសេនេទិកសត្វ ចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមចំណីសត្វ បសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល ត្រូវបញ្ចប់ការផ្គត់ផ្គង់ចែកចាយបន្តទៀតក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ។

**មាត្រា ១២៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកំពុងដំណើរការក្រោមការអនុញ្ញាតណាមួយដែលមានសុពលភាពនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបំពេញសំណុំបែបបទស្នើសុំការអនុញ្ញាតឡើងវិញ និងស្នើសុំការចុះបញ្ជីជាថ្មី តាមនីតិវិធីដែលកំណត់ដោយច្បាប់នេះ ក្នុងរយៈពេលមិនលើសពី ១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ។

## ជំពូកទី ២២

## អវសានប្បញ្ញត្តិ

**មាត្រា ១២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស. ១៦០១. ១១៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ហត្ថលេខា**

**អ៊ុក រ៉ាប៊ុន**

លេខ: ១០០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**



**សយ សុខា**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

## សទ្ទានុក្រម

១- **កន្លែងឆ្លងជំងឺ** សំដៅដល់ទីតាំងណាមួយ ទីកន្លែងណាមួយ អគារ ទីកន្លែងចិញ្ចឹមសត្វមានមេរោគបង្កជំងឺ ឬជឿថាមានមេរោគជំងឺវិញ្ញត្តិដែលត្រូវបានប្រកាសដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

២- **ការកែច្នៃបឋមផលិតផលសត្វ** សំដៅដល់ការបំលែងផលិតផលសត្វតាមរយៈដំណើរការនៃការកែច្នៃមានជាអាទិ៍ ការពិឃាត ការពន្លាត់ស្បែក ការសម្អាត ការហាលសម្ងួត ការឆ្អើរ ការក្លាស្សេ ការបង្កក ការស្ងោរ ការចំហុយ ការអាំង ការដុត ការផ្អាប់ ការកិន ការប្រឡាក់អំបិល ការវេចខ្ចប់ ការរក្សាទុកតាមបច្ចេកទេសចម្អិនផ្សេងៗ ។

៣- **ការកម្ទេចចោល** សំដៅដល់ការសម្លាប់ ការបំផ្លាញចោល បំបែកជាបំណែកធ្វើឲ្យបាត់សមត្ថភាពដើមតាមវិធានការបសុព្យាបាល ។

៤- **ការឃ្លាំមើល** សំដៅដល់ការប្រមូល និងការវិភាគព័ត៌មានជាលក្ខណៈប្រព័ន្ធទាក់ទងនឹងសុខភាពសត្វ ក្នុងគោលបំណងរកឲ្យឃើញជាមុន ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានឲ្យបានទាន់ពេលវេលាដល់អ្នកពាក់ព័ន្ធ សំដៅចាត់វិធានការទប់ស្កាត់ជំងឺសត្វដែលមានឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិ សុវត្ថិភាពម្ហូបអាហារ និងពាណិជ្ជកម្ម ។

៥- **ការដាក់កំហិត** សំដៅដល់ការកំណត់លក្ខខណ្ឌការរឹតបន្តឹងចរាចរណ៍សត្វ ផលិតផលសត្វ ឧបករណ៍សម្ភារ និងមធ្យោបាយដឹកជញ្ជូនពាក់ព័ន្ធដទៃទៀតដើម្បីកុំឲ្យជំងឺឆ្លងរាលដាល ។

៦- **ការតាមដាន** សំដៅដល់ការប្រមូលព័ត៌មាន សង្កេតត្រួតពិនិត្យជាប្រចាំស្តីពីជំងឺសត្វ ផលិតភាព និងគុណភាពផលិតផលសត្វ បសុឱសថចំណីសត្វ ក្នុងគោលបំណងរកឲ្យឃើញការប្រែប្រួលក្នុងបរិស្ថាន ឬការប្រែប្រួលស្ថានភាពសុខភាពសត្វ ។

៧- **ការត្រួតពិនិត្យអនាម័យបសុព្យាបាល** សំដៅដល់ការត្រួតពិនិត្យអនាម័យដោយមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វលើសត្វ ផលិតផលសត្វ បសុឱសថចំណីសត្វដើម្បីកំណត់នូវវត្តមានវត្ថុធាតុជីវសាស្ត្រ គីមីសាស្ត្រ រូបសាស្ត្រ ឬធាតុវិទ្យុសកម្មដែលបណ្តាលឲ្យមានគ្រោះថ្នាក់ចំពោះសុខភាពសត្វ សុខភាពមនុស្ស និងបរិស្ថាន ។

៨- **ការបោះបង់ចោល** សំដៅដល់ការបោះបង់កម្មសិទ្ធិ ឬការជម្លៀសចេញពីបរិវេណកម្មសិទ្ធិទៅកន្លែងទីទៃនូវសត្វរស់ ឬស្លាប់ ផលិតផលសត្វ បសុឱសថចំណីសត្វ ឧបករណ៍ ឬសម្ភារដទៃទៀតដោយគ្មានការអនុញ្ញាត ឬដែលមិនអនុវត្តតាមវិធានការបសុព្យាបាល ។

៩- **ការសម្លាប់មេរោគ** សំដៅដល់ការអនុវត្តនូវវិធានការនានាក្នុងគោលបំណងកម្ទេចភ្នាក់ងារបង្ករោគ ឬប៉ារ៉ាស៊ីតក្រោយពេលលាងសម្អាតដែលអនុវត្តចំពោះកន្លែងមធ្យោបាយដឹកជញ្ជូន និងឧបករណ៍ សម្ភារដែលប៉ះពាល់មេរោគដោយផ្ទាល់ ឬដោយប្រយោល ។

១០- **ការអង្កេតអេពីដេមីសាស្ត្រ**សំដៅដល់ការកំណត់ប្រភពនិងមូលហេតុនៃការផ្ទុះជំងឺព័ត៌មានអំពីបរិស្ថានមេកានិចនៃការចម្លងកំណត់វិសាលភាពនៃការចម្លង និងរៀបចំយុទ្ធវិធីសម្រាប់បង្ការទប់ស្កាត់ និងលុបបំបាត់ជំងឺ ។

១១- **ចត្តាឡីស័ក** សំដៅដល់រាល់សកម្មភាពដឹកនាំដោយមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចដើម្បីបង្ខាំងសត្វផលិតផលសត្វ ឧបករណ៍ សម្ភារ និងមធ្យោបាយដឹកជញ្ជូនដែលប៉ះពាល់សត្វ ឬផលិតផលសត្វ ដើម្បីត្រួតពិនិត្យអនាម័យបង្ការ និងទប់ស្កាត់ជំងឺ ។

១២-**ចរាចរណ៍សត្វ** សំដៅដល់បន្លាស់ទីសត្វពីទីកន្លែងមួយទៅទីកន្លែងមួយទៀតតាមគ្រប់រូបភាព ។

១៣-**ចំណីសត្វ** សំដៅដល់វត្ថុធាតុទាំងអស់រួមមានវត្ថុធាតុដើម សារធាតុបន្ថែម និងសារធាតុលាយផ្សំដទៃទៀត ( សមាសភាគតែមួយ ឬច្រើនមុខ ) ដែលកែច្នៃ ពាក់កណ្ដាលកែច្នៃ ឬមិនទាន់កែច្នៃក្នុងគោលបំណងយកមកប្រើប្រាស់ជាចំណីសត្វ ។

១៤- **ជំងឺវិញ្ញត្តិ** សំដៅដល់ជំងឺឆ្លង ដែលមានចែងក្នុងបញ្ជីឈ្មោះជំងឺសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយអនុលោមតាមបទប្បញ្ញត្តិជាតិ ។ ជំងឺនេះមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស សត្វ ឬបរិស្ថាន ឬមានសក្តានុពលបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គម ឬពាណិជ្ជកម្ម ។

១៥- **ជំងឺស៊ូណូស** សំដៅដល់បណ្ដាប្រភេទជំងឺដែលឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ។

១៦- **តំបន់គ្មានជំងឺ** សំដៅដល់តំបន់ដែលគ្មានវត្តមានជំងឺដោយអនុលោមតាមការតម្រូវសម្រាប់ស្ថានភាព «គ្មានជំងឺ» ដែលបានកំណត់នៅក្នុងក្រមរបស់អង្គការសុខភាពសត្វពិភពលោក ឬនៅក្នុងតំបន់ និងនៅតាមព្រំប្រទល់នៃតំបន់នោះមានមន្ត្រីសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចត្រួតពិនិត្យសត្វ ផលិតផលសត្វ និងមធ្យោបាយដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ។

១៧-**តំបន់ទប់ស្កាត់ជំងឺ** សំដៅដល់ដែនដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តវិធានការអនាម័យក្នុងគោលបំណងទប់ស្កាត់ជំងឺ និងសម្រួលពាណិជ្ជកម្ម ។ តំបន់ទប់ស្កាត់ជំងឺរួមមាន ដែនហាមឃាត់ ដែនទប់ស្កាត់តំបន់មានជំងឺឆ្លងរាលដាលតំបន់ទ្រនាប់និងតំបន់ឃ្លាំមើល ។

១៨- **ទប់ស្កាត់** សំដៅដល់សកម្មភាពបង្ការ និងរាំងជំងឺក្នុងគោលបំណងកាត់បន្ថយអត្រាឈឺ និងស្លាប់ [illegible] ទាំងរាំងការឆ្លងរីករាលដាលជំងឺដល់សត្វ មនុស្ស និងប៉ះពាល់ដល់បរិស្ថាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

**១៩- ទីកន្លែង** សំដៅដល់គ្រឹះស្ថាន ឬទីធ្លាបរិវេណដោយរាប់បញ្ចូលទាំងអគារសម្ភារ និងឧបករណ៍បំពាក់ដែលប្រើប្រាស់សម្រាប់គោលបំណងរួមជាក់លាក់ ។

**២០-ទីកន្លែងប្រមូលផ្តុំក្បាលសត្វ** សំដៅដល់ទីកន្លែងបំប៉នសត្វ បង្វឹកសត្វ ទីកន្លែងសំណាក់សត្វ របើសសត្វ ទីកន្លែងស្តុកសត្វ និងទីកន្លែងប្រមូលផ្តុំសត្វសម្រាប់គោលបំណងផ្សេងទៀត ។

**២១-ទីកន្លែងព្យាបាលសត្វ** សំដៅដល់មន្ទីរពេទ្យសត្វគ្លីនិកសត្វ និងបន្ទប់ព្យាបាលសត្វ ។

**២២-ទីកន្លែងអាជីវកម្មសត្វ** សំដៅដល់ទីកន្លែងទិញលក់សត្វ ផ្សារសត្វ និងទីកន្លែងធ្វើអាជីវកម្មផ្សេងទៀត ។

**២៣-ទីតាំងជីវសុវត្ថិភាព** សំដៅដល់ទីកន្លែងមួយ ឬច្រើនដែលចិញ្ចឹមសត្វស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងជីវសុវត្ថិភាពរួមមួយដោយមានស្ថានភាពសុខភាពជាក់លាក់ទៅនឹងជំងឺមួយ ឬច្រើន ដែលទាមទារការប្រើប្រាស់ការឃ្លាំមើលការទប់ស្កាត់ និងវិធានជីវសុវត្ថិភាពដែលមានប្រយោជន៍សម្រាប់ពាណិជ្ជកម្ម ។

**២៤-បសុពេទ្យ** សំដៅដល់នីតិជនដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វកម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងដែលមានការទទួលស្គាល់ពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**២៥-បមាណីយ** សំដៅដល់ប្រព័ន្ធបទបញ្ញាអប្បបរមាគំរូដែលជាការតម្រូវសម្រាប់អនុវត្តនៅក្នុងប្រតិបត្តិការដែលពាក់ព័ន្ធផលិតកម្មសត្វ សុខភាពសត្វ ជាពិសេសចំណីសត្វ សារធាតុបន្ថែម ឬបសុឱសថគ្រប់ប្រភេទ ដើម្បីឆ្លើយតបចំពោះការធានាប្រសិទ្ធភាព និងសុវត្ថិភាព ដូចមានចែងក្នុងច្បាប់នេះ ។

**២៦-បសុឱសថ** សំដៅដល់សារធាតុមួយមុខ ឬបន្សំសារធាតុច្រើនមុខដែលមានប្រភពពីសារធាតុជាតិគីមី ជីវផលិតផលជាតិ អតិសុខុមប្រាណ រុក្ខជាតិដែលផលិតលាយផ្សំឡើងដើម្បីប្រើប្រាស់សម្រាប់សត្វ ៖

- ក្នុងការបង្ការឬព្យាបាលជំងឺ
- ស្រាវជ្រាវវេជ្ជសាស្ត្រឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ
- កែប្រែ ឬទ្រទ្រង់មុខងារនៃសរីរាង្គ ។

ត្រូវបានចាត់ទុកជាបសុឱសថដែររួមមានសេរ៉ូមឬវ៉ាក់សាំងសត្វឈាម ឬផលិតផលដែលបានមកពីឈាមសត្វ ឱសថបុរាណ ផលិតផលដែលផ្សំឡើងដោយមានជាតិពុល ដែលមានក្នុងបញ្ជីកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**២៧-ផលិតផលមានដើមកំណើតពីសត្វ** សំដៅដល់ ៖

- ផលិតផលដែលមានដើមកំណើតពីសត្វសម្រាប់មនុស្សបរិភោគដែលរួមមានសាច់សត្វស្រស់ ផលិតផលសាច់ សាច់ឡាទីនស៊ុត ផលិតផលស៊ុត ទឹកដោះ ផលិតផលទឹកដោះ និងទឹកឃ្មុំ

- ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើប្រាស់ក្នុងកសិកម្ម និងឧស្សាហកម្ម
- ផលិតផលមានដើមកំណើតពីសត្វសម្រាប់ប្រើប្រាស់ក្នុងការផលិតឱសថ ឬវះកាត់ដែលរួមមានសរីរាង្គសត្វជាលិកា និងសារធាតុរាវសរីរាង្គដែលត្រូវបានប្រើប្រាស់ក្នុងការផលិតឱសថ ឬសម្ភារវះកាត់
- ផលិតផលមានដើមកំណើតពីសត្វប្រើប្រាស់សម្រាប់ការផលិត លាយផ្សំចំណីសត្វដែលមានជាអាទិ៍ ម្សៅសាច់ ម្សៅថ្លើម ម្សៅឆ្អឹង ម្សៅឈាម ម្សៅត្រី ម្សៅរោមសត្វ ខ្លាញ់សត្វ ផលិតផលទឹកដោះ ។

២៨-**ផលិតផលសត្វ** សំដៅដល់ផ្ទាំងសាច់ ឬផ្នែកណាមួយនៃផ្ទាំងសាច់ផលិតផលមានដើមកំណើតពីសត្វ វត្ថុធាតុសេនេទិកសត្វ វត្ថុធាតុរោគសាស្ត្រសត្វ លាមកសត្វ និងទឹកមូត្រ ។

២៩-**ផលិតផលសាច់** សំដៅដល់សាច់ដែលត្រូវបានធ្វើប្រព្រឹត្តកម្មដោយបម្លែងលក្ខណៈសរីរៈ លក្ខណៈរូប និងលក្ខណៈគីមីសរីរៈរបស់វា ។

៣០-**ភាពអាសន្ននៃជំងឺសត្វ** សំដៅដល់វត្តមាននៃការផ្ទុះ ឬអាចផ្ទុះជំងឺវិញ្ញត្តិ ។

៣១-**ភ្នាក់ងារបសុពេទ្យ** សំដៅដល់នីតិជនដែលមានសញ្ញាបត្រកម្រិតបឋមផ្នែកផលិតកម្មសត្វ និងបសុព្យាបាល ឬសញ្ញាបត្រសមមូល ។

៣២-**មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ** សំដៅដល់បសុពេទ្យរបស់រដ្ឋដែលត្រូវបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តការត្រួតពិនិត្យអនាម័យបសុព្យាបាល អនុវត្តវិធានការអនាម័យ ទប់ស្កាត់ អង្កេតតាមដានធ្វើរបាយការណ៍លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងការងារពាក់ព័ន្ធដទៃទៀត ។

៣៣-**មន្ទីរព្យាបាលសត្វ** សំដៅដល់មន្ទីរពេទ្យសត្វ និងកន្លែងពិនិត្យព្យាបាលសត្វគ្រប់ខ្នាតរបស់រដ្ឋ និងឯកជន ។

៣៤-**រេអាក់ទីហ្វ** សំដៅដល់សារធាតុដែលធ្វើប្រតិកម្មដោយផ្ទាល់ ឬធ្វើប្រតិកម្មចម្លង សម្រាប់ប្រើប្រាស់ក្នុងការធ្វើតេស្ត វិភាគ និងធ្វើរោគវិនិច្ឆ័យនៅក្នុងមន្ទីរពិសោធន៍ ។

៣៥-**វត្ថុធាតុរោគសាស្ត្រ** សំដៅដល់ផ្នែកណាមួយ ឬទាំងមូលនៃជាលិកា ឬសរីរាង្គដែលមាននៅលើសត្វរស់ ឬសត្វស្លាប់ និងដែលមានបម្រែបម្រួលខុសប្រក្រតីទាំងលក្ខណៈ រូបលក្ខណៈគីមី ឬលក្ខណៈជីវៈហើយសង្ស័យថាមានរោគមានភ្នាក់ងារចម្លងជំងឺឆ្លង ឬជំងឺប៉ារ៉ាស៊ីត ។

៣៦- **វត្ថុធាតុដើម** សំដៅដល់ផលិតផលមានប្រភពពីបន្លែរុក្ខជាតិ ឬសត្វស្ថិតក្នុងលក្ខខណ្ឌធម្មជាតិស្រស់ ស្ងួត ផ្អាប់ ឬរក្សាទុកឲ្យបានយូរផលិតផលមានប្រភពពីការកែច្នៃឧស្សាហកម្ម និងសារធាតុសរីរាង្គ ឬអសរីរាង្គដោយផលិតផលទាំងអស់នេះ សម្រាប់ប្រើប្រាស់ជាចំណីសត្វ ។

**៣៧-វត្ថុវិភាគ** សំដៅដល់សត្វទាំងមូលផ្នែកណាមួយ ឬសរីរាង្គណាមួយរបស់សត្វឈាមសេរ៉ូមស្លេស្ម សំបោរលាមកទឹកមូត្រផលិតផលសត្វ ផលិតផលសាច់ បសុឱសថចំណីសត្វ ដែលត្រូវបានយកទៅធ្វើវិភាគ ។

**៣៨-វិញ្ញាបនបត្របសុព្យាបាល** សំដៅដល់លិខិតបញ្ជាក់ជាផ្លូវការ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចលើវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៃប្រទេសណាមួយដែលពិពណ៌នាអំពីតម្រូវការសុខភាពសត្វ ឬសុខភាពសាធារណៈដែលធ្វើចំពោះសត្វ ឬផលិតផលសត្វសម្រាប់ចរាចរណ៍ដោយអនុលោមទៅតាមលក្ខខណ្ឌបទដ្ឋានបច្ចេកទេសរបស់អង្គការសុខភាពសត្វពិភពលោក ។

**៣៩-វិធានការអនាម័យ** សំដៅដល់វិធានការដើម្បីការពារសុខភាពសត្វ ឬសុខភាពមនុស្ស ឬបរិស្ថានពីហានិភ័យដែលកើតឡើងដោយសារការនាំចូល ការបង្កើត និងការសាយភាយភ្នាក់ងារជីវសាស្ត្រគីមីសាស្ត្រ ឬរូបសាស្ត្រ ។ វិធានការមានជាអាទិ៍ការសង្កេត ស្រាវជ្រាវ ការដាក់ឲ្យនៅដោយឡែកចត្តាឡីស័កការបង្ការ និងការព្យាបាល ការសម្អាត ការសម្លាប់ ការកម្ទេចចោលមេរោគ និងសត្វចង្រៃ ។

**៤០-សត្តឃាតដ្ឋាន** សំដៅដល់ទីកន្លែងដែលសត្វត្រូវបានពិឃាតយកសាច់ផលិតផលសត្វ ដើម្បីធ្វើអាជីវកម្ម ។

**៤១- សត្វ** សំដៅដល់ថនិកសត្វ បក្សី ឬឃ្មុំ ។

**៤២-សាច់** សំដៅដល់ផ្នែកទាំងអស់របស់សត្វ ដែលអាចបរិភោគបាន ។

**៤៣- សារធាតុបន្ថែម** សំដៅដល់សារធាតុ ដែលត្រូវបានដាក់បន្ថែមទៅក្នុងវត្ថុធាតុដើម ឬចំណីសត្វក្នុងគោលបំណងកែប្រែរសជាតិ ក្លិន រូបរាង ឬលក្ខណៈរូបសាស្ត្រដទៃទៀត ឬដើម្បីបង្កើនភាពរំលាយអាហារការស្រូបយក ឬភាពធន់នឹងការខូចខាត ។

**៤៤- សារធាតុសកម្ម** សំដៅដល់សារធាតុចាំបាច់ចម្បងដែលមាននៅក្នុងបសុឱសថ ឬចំណីសត្វ ។

**៤៥- សុខភាពសាធារណៈបសុព្យាបាល** សំដៅដល់រាល់សកម្មភាពនៅក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វក្នុងគោលបំណងទប់ស្កាត់ និងលុបបំបាត់ជំងឺស៊ូណូស និងការពារសុវត្ថិភាពម្ហូបអាហារ ។

**៤៦- សុខុមាលភាពសត្វ** សំដៅដល់ស្ថានភាព ឬលក្ខខណ្ឌរស់នៅរបស់សត្វដូចជា សត្វមានសុខភាពល្អ ផ្តល់ចំណីអាហារគ្រប់គ្រាន់ រស់នៅមានសុវត្ថិភាព មានជម្រកសមរម្យ ការចិញ្ចឹម ការប្រើប្រាស់ ការដឹកជញ្ជូន និងការពិឃាតតាមបែបមនុស្សធម៌ ។

**៤៧-ស្ថានីយចត្តាឡីស័ក** សំដៅដល់ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ឬផលិតផលសត្វដែលត្រូវបានរក្សាទុកនៅដាច់ដោយឡែក ដើម្បីចាត់វិធានការបសុព្យាបាលដោយអនុលោមតាមបទដ្ឋានពាណិជ្ជកម្មអន្តរជាតិ ស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

**៤៨- សុពលភាពផ្គត់ផ្គង់ចែកចាយ** សំដៅដល់ការងារក្រោយការចុះបញ្ជី ដែលអនុវត្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់លិខិតអនុញ្ញាតឲ្យធ្វើការនាំចូល ការផលិត ការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីបសុឱសថ ឬចំណីសត្វ ដើម្បីទទួលបាននូវសិទ្ធិធ្វើការផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅក្រោយពេលដែលលទ្ធផលវិភាគលើវត្ថុវិភាគ ដែលត្រូវបានមន្ត្រីអធិការកិច្ចមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រា ដើម្បីផ្ទៀងផ្ទាត់ឡើងវិញលើបមាណីយ និងលក្ខខណ្ឌបទដ្ឋានបច្ចេកទេស ឃើញថាពុំមានភាពប្រែប្រួលខុសពីការបញ្ជាក់អះអាងនៅពេលស្នើសុំការចុះបញ្ជីហើយអ្នកកាន់លិខិតអនុញ្ញាតបានអនុវត្តតាមគ្រប់ការតម្រូវបមាណីយ និងលក្ខខណ្ឌបទដ្ឋានបច្ចេកទេសដែលកំណត់ដោយច្បាប់នេះ ។

**៤៩- ស្លាកសញ្ញាព័ត៌មាន** សំដៅដល់ស្លាកសញ្ញាដែលសរសេរបោះពុម្ព ឬជាក្រាហ្វិកមានឈ្មោះពាណិជ្ជសញ្ញា សមាសធាតុ របៀបប្រើប្រាស់ កាលបរិច្ឆេទ ។ល។ សម្រាប់ភ្ជាប់ទៅនឹងផលិតផលសត្វ ផលិតផលសាច់ចំណីសត្វវត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់ការផលិតនិងការលាយផ្សំបសុឱសថ ចំណីសត្វ សារធាតុសកម្ម ឬសមាសធាតុបសុឱសថ នៅលើសំបកវេចខ្ចប់ផ្នែកខាងក្នុង ឬខាងក្រៅ ដូចជាដប កំប៉ុង អំពូល បាវ ថង់ ប្រអប់ ។ល។

**៥០- អត្តសញ្ញាណកម្មសត្វ** សំដៅដល់ការប្រើប្រាស់លើគ្រប់មធ្យោបាយដើម្បីកំណត់អត្តសញ្ញាណសត្វ ដើម្បីផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងស្ថិតិសត្វ ចរាចរណ៍សត្វ ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការធ្វើពាណិជ្ជកម្មសត្វ ការត្រួតពិនិត្យអនាម័យសត្វ ការទប់ស្កាត់ជំងឺឆ្លងរាលដាល និងការសម្គាល់កម្មសិទ្ធិសត្វ ។

**៥១- អធិការកិច្ច** សំដៅដល់ការចុះត្រួតពិនិត្យ ចាត់វិធានការបច្ចេកទេស និងវិធានការច្បាប់លើសកម្មភាព និងទីកន្លែងចិញ្ចឹមសត្វ ទីកន្លែងបង្កាត់ពូជសត្វ មន្ទីរព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ ទីកន្លែងអាជីវកម្មសត្វ សត្តឃាតដ្ឋាន ទីកន្លែងកែច្នៃផលិតផលសត្វ ទីកន្លែងប្រមូលផ្តុំ ឬលក់ផលិតផលសត្វ ទីកន្លែងផលិតលាយផ្សំ ឬលក់ចំណីសត្វ និងទីកន្លែងផលិតលាយផ្សំ ឬលក់បសុឱសថ ឬទីកន្លែងដទៃទៀតដែលពាក់ព័ន្ធវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

**៥២-អាជីវកម្មសត្វ** សំដៅដល់ការទិញ លក់ ដូរ ដឹកជញ្ជូន និងពិឃាតសត្វ ។

**៥៣-អ្នកបច្ចេកទេសបសុពេទ្យ** សំដៅដល់នីតិជនដែលមានសញ្ញាបត្របរិញ្ញាបត្រវេងបច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្មផ្នែកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ ឬសញ្ញាបត្រមធ្យមផ្នែកផលិតកម្ម និងបសុព្យាបាល ឬសញ្ញាបត្រសមមូល ។